នួន ឃឿន

# ដំណើរឆ្ពោះទៅទិសខាងលិច
# និង
# ឥស្សរិជនក្នុងឆ្នាំ២០០០



នួន-ឃឿន

# ដំណើរឆ្ពោះទៅទិសខាងលិច

និង

# ឥណ្ឌូចិនក្នុងឆ្នាំ ២០០០

[ សាកល្បង ]

ការផ្សាយរបស់អ្នកនិពន្ធ

រក្សាសិទ្ធ

បោះពុម្ពលើកទី ១ ចំនួន ២, ០០០ ច្បាប់
តម្កល់ទុកតាមលេខ ១១៦២ ចុះថ្ងៃទី ៩ វិច្ឆិកា ឆ្នាំ១៩៧០
បោះនៅក្រុមហ៊ុនរោងពុម្ពខ្មែរ

ព.ស. ២៥១៤     គ.ស. ១៩៧០

# អារម្ភកថា

*វិភាគទានដ៏វិសេសវិសាលដែលជនជាតិខ្មែរម្នាក់ៗ អាចផ្តល់ចំពោះមាតុប្រទេសរបស់ខ្លួន ដើម្បីឲ្យជាតិរបស់ខ្លួននៅគង់វង្សជីវិតក្នុងបណ្តាភូមិភាគមួយដែលប្រកបដោយគ្រោះថ្នាក់នោះ គឺការស្គាល់តម្លៃវប្បធម៌ អារ្យធម៌ និងជាពិសេសប្រវត្តិសាស្ត្រជាតិខ្លួននេះឯង ។*

*ប្រវត្តិសាស្ត្រកត់ត្រាទុកគ្រប់កំហុស ដែលដូនតាយើងបានប្រព្រឹត្តរួចមកហើយក្នុងអតីតកាល ព្រមទាំងភាពថ្កុំថ្កើងរុងរឿងដែលបានធ្វើឲ្យវាសនាប្រជាជាតិខ្មែរ និងវប្បធម៌ខ្មែរអណ្តែតត្រសែតខ្ពង់ខ្ពស់ ក្នុងពពកនៃពន្លឺត្រចះត្រចង់ៗ អំពើឬព្រឹត្តិការណ៍ទាំងនេះទោះជាផ្តល់ដល់ប្រជាជាតិយើងនូវកេរ្តិ៍ឈ្មោះរន្ទឺសុះសាយក្តី ឬក៏ភាពអាមាសមុខពន់ប្រមាណក្តី ដែលមានថែងនៅលើគ្រប់ទំព័រនៃពង្សាវតារជាតិ ក៏អំពើទាំងឡាយនោះឯងជាកេរ្តិ៍មរតកឥតកាត់តម្លៃបានដែលយើងទទួលអំពីដូនតាយើងមក ។*

*គឺអំពើ ឬព្រឹត្តិការណ៍ទាំងនេះហើយ ដែលបង្កើតនូវសម្បជញ្ញៈខ្មែរៗ ជនជាតិខ្មែរសម័យនេះ ជាលទ្ធផលនៃអតីតកាល ឬជាលទ្ធផលនៃសម្បជញ្ញៈខ្មែរនេះឯង ។*

*ពិតមែនហើយដែលថាក្នុងប្រវត្តិសាស្ត្រនៃប្រទេសយើង យើងបានឆ្លងកាត់នូវភាពអាមាសមុខយ៉ាងច្រើន ចាប់តាំងពីសតវត្សទី១៣ រហូតដល់សម័យបច្ចុប្បន្នកាលនេះ ក្រោយពីបានស្គាល់ភាពរុងរឿងអស់រយៈពេលដ៏យូរ (ពីសតវត្សទី៨ មកសតវត្សទី១៣) ក្តី, តែប្រជាជាតិយើង, ពូជសាសន៍យើង, វប្បធម៌និងអារ្យធម៌យើងមិនបានរលាយសូន្យ បាត់ស្រមោលពីសាកលលោកឡើយៗ អារ្យធម៌ជាច្រើនក្នុងលោកនេះ ដែលធ្លាប់បានស្គាល់ភាពរុងរឿងត្រចះត្រចង់ក្នុងអតីតកាល ខ្លះត្រូវទទួលវាសនាអាក្រក់ធ្លាក់ចុះទៅក្នុងពិភពងងឹតនៃការភ្លេចភ្លាំងរបស់មនុស្ស ឬក៏រលាយបាត់ស្រមោលសូន្យសុងពីសម្បជញ្ញៈមនុស្សជាតិ ដូចមានអារ្យធម៌កាលដេ (Chaldée), អាស៊ីរី (Assyrie), ក្រិក (Grèce), ឬ រ៉ូម (Rome) ។ល។*

*ដូច្នេះ ប្រជាជាតិយើង អារ្យធម៌យើង ដែលបានតស៊ូទប់ទល់នឹងការឈ្លានពានឥតឈប់ឈរអំពីអ្នកជិតខាងឥតសប្បុរសធម៌ តាំងពីជាង ៦ សតវត្សរួចមកហើយតែមិនព្រមចុះចាញ់ មិនព្រមទម្លាក់អាវុធចុះញ៉មវាសនាអកុសលរបស់ខ្លួននោះ នេះជា*

វាសនាដ៏ឧត្តុង្គឧត្តមមួយណាស់ទៅហើយ ។ នៅសតវត្សទី១៩, ប្រជាជាតិខ្មែរយើងមានបណ្ដាជនមិនបានដល់មួយលាននាក់ផង ( ប្រហែលជា ៨០០, ០០០ នាក់ បើតាមអស់លោកអ្នកប្រាជ្ញបារាំង ដែលបានមកទស្សនានិងសិក្សាប្រទេសយើងជាលើកដំបូង ) សម័យនោះ យើងស្មានតែយើងបានស្គាល់ទីបំផុតនៃជីវិតរបស់ប្រជាជាតិយើងរួចទៅហើយ តែយើងបែរជារស់រានមានជីវិតឡើងវិញ។ ហើយមិនត្រឹមតែរស់ឡើងវិញប៉ុណ្ណោះទេ ថែមទាំងបានរៀបចំរដ្ឋយើងអនុលោមទៅតាមសម័យទំនើបវិទ្យាសាស្ត្រទៀតផង។ ហើយថ្មីៗនេះទៀត របបសក្តិភូមិរាជានិយមផ្ដាច់ការដែលជាទម្ងន់មួយធ្ងន់ពន់ប្រមាណមកលើវាសនាខ្មែរគ្រប់ៗរូប និងជាប្រកតនៃភាពអោនថយរបស់ប្រជាជាតិយើងនោះទៀត, ឥឡូវយើងបានវាយកំទេចបំផ្លាញរបបចង្រៃនេះ យកជ័យជំនះជាស្រេចលើរបបនោះរួចទៅហើយ ។

ម្ដងនេះ យើងនឹងស្គាល់ជាថ្មីម្ដងទៀត នូវពន្លឺនៃសេចក្ដីថ្លៃថ្នូរ នៃសេចក្ដីក្លាហាន និងសេរីភាព។ យើងអស់ឧបសគ្គអ្វីមករាំងក្នុងដំណើរយើងទៅកាន់ការចាប់កំណើតរស់ឡើងវិញ នៃប្រជាជាតិយើងទៀតហើយ ។

មួយចំណែកទៀត, ប្រជាជនយើងក្នុងសម័យនេះមានរហូតដល់ ៨ លាននាក់, នោះបើយើងមិនរាប់ខ្មែរនៅយៀកណាមខាងត្បូង និងនៅថៃឡង់ ដែលមានចំនួនពី ៣ ទៅ ៤ លានទៀតផង ។ ក្នុង ៣០ ឆ្នាំទៀត ប្រជាជននៅក្នុងដែនដីកម្ពុជាសព្វថ្ងៃនេះនឹងកើនទៅដល់ ១៥ លាននាក់ហើយ។ បើយ៉ាងដូច្នេះ, តើសត្រូវណា អ្នកជិតខាងឯណា ឬមហាអំណាចឯណាក្នុងលោកនឹងអាចកាប់សម្លាប់ បំផ្លិចបំផ្លាញជាតិខ្មែរពី ៨ ទៅ ១៥ លានអស់បានដែរឬ ?

វាសនារបស់ប្រជាជាតិយើងក្នុងអនាគតកាល គឺយើងត្រូវតែរស់។ តែត្រង់ចំណុចថារស់បែបណាៗ នោះ គឺ “រស់គ្រាន់តែរស់” ឬរស់ក្នុងសេចក្ដីចំរើនក្នុងភាពថ្លៃថ្នូរនោះ នេះជាបញ្ហាមួយទៀតដ៏ធំដែលយើងរាល់គ្នាត្រូវតែគិតដោះស្រាយ ព្រោះបើ “រស់គ្រាន់តែរស់” ដោយគ្រហេបគ្រហប ស៊ើររស់ស៊ើរស្លាប់ រស់ក្នុងបណ្ដាការខ្វះសេចក្ដីថ្លៃថ្នូរ អយុត្តិធម៌ វេទនាថយថោក... ប៉ុណ្ណោះទេ, នោះស្លាប់ទៅវាប្រសើរជាងដើម្បីកុំឲ្យសេចក្ដីលំបាកវេទនា ឈឺចាប់ខ្លោចផ្សា ដែលធ្លាប់មានអស់រយៈជាង ៦ សតវត្សទៅហើយនោះចេះតែបន្តទៅទៀត ។

ការរៀបចំប្រជាជាតិខ្មែរ រដ្ឋខ្មែរឡើងវិញ ស្របទៅតាមគោលការនៃលទ្ធិប្រជាធិបតេយ្យ តាមផ្លូវនយោបាយ (Démocratie Politique) និងតាមផ្លូវសង្គម (Démocratie sociale) គឺជាការចាំបាច់ជាមូលដ្ឋាន នៃប្រទេសកម្ពុជាសម័យថ្មី ។

អ្នកនិពន្ធនៃសៀវភៅដ៏តូចនេះយល់ថា ដរាបណាគំនិតប្រជាធិបតេយ្យ សេរីភាព ស្ថិតនៅតែលើក្រដាស មិនព្រមក្លាយទៅជាការពិតជាក់ស្តែងក្នុងកិច្ចការប្រតិបត្តិក្នុងជីវភាពរាល់ថ្ងៃរបស់រាស្ត្រខ្មែរគ្រប់រូប ឬនៅតាមភូមិជនបទទេនោះ ដរាបនោះយើងមិនអាចរំដោះជនជាតិខ្មែរ ឬប្រជាជាតិខ្មែរពីភាពបាក់ស្បាតតក់ស្លុត ចុះញ៉មមុនប្រយុទ្ធ សេចក្តីល្ងង់ខ្លៅ ឬការគ្មានជំនឿទៅលើខ្លួនឯងនោះបានឡើយ ។

គ្មានអ្វីពិបាកជាងការផ្លាស់ប្តូរ បោះបង់ផ្នត់គំនិតចាស់មួយដែលមានអាយុរាប់សតវត្សរួចមកហើយនោះទេ។ តែនោះក៏មិនមែនកិច្ចមួយដែលគេមិនអាចសម្រេចបាននោះក៏ទេដែរ ។ សេចក្តីក្លាហាន បូកនិងការប៉ិនប្រសប់របស់អ្នកនយោបាយខ្មែរ ក្នុងក្របខណ្ឌនៃយុទ្ធវិធីមួយ ដែលតម្រូវនឹងចិត្តគំនិតខ្មែរ សង្គមខ្មែរពិតប្រាកដជាការពិ-បាកណាស់ តែជាការចាំបាច់ជាបឋមដើម្បីសំរេចនូវបដិវត្តន៍ខ្មែរ ។

x x x

គំនិតដែលលោកអ្នកអាននឹងឃើញក្នុងសៀវភៅដ៏តូចនេះ ប្រហែលជាលឿនពេក ឬក៏ហ៊ានពេក ឬមួយក៏អាចបណ្តាលឲ្យមានការស្រងាកចិត្តខ្លះក៏សឹងមាន ។ អ្នកអានខ្លះអាចចោទអ្នកនិពន្ធថា ជាអ្នកមានគំនិតទុទិដ្ឋិនិយម ។ល។

អ្នកនិពន្ធទំព័រទាំងនេះ ជាខ្មែរមួយរូបមានកំណើតនៅចម្ងាយ ៦ គីឡូម៉ែត្រពីអង្គរវត្ត បានទទួលការអប់រំមិនឆ្ងាយប៉ុន្មានពីអង្គរវត្ត បានស្គាល់ហើយស្រឡាញ់អង្គរវត្តដូចជាទ្រព្យសម្បត្តិរបស់ខ្លួនផ្ទាល់ បានធំពេញវ័យចំណោមមហាប្រាង្គសិលា ជាកំណប់នៃវប្បធម៌ អារ្យធម៌ ប្រវត្តិសាស្ត្រខ្មែរ សុទ្ធសឹងជាកេរ្តិ៍មតិកនៃភាពរុងរឿងសម័យដើមមហានគរ ។ ជាការធម្មតា ការស្គាល់និងការស្រឡាញ់ប្រកពនៃអារ្យធម៌ខ្មែរ និងប្រជាជាតិខ្មែរនេះ ជម្រុញចិត្តឲ្យមានការនឹកស្រណោះដល់អតីតកាល ចង់ឃើញប្រជាជាតិខ្មែរក្លាយទៅជាពិភពមួយរុងរឿងត្រចះត្រចង់ដូចដែលខ្មែរធ្លាប់ស្គាល់ក្នុងអតីតកាលសម័យ "មហានគរ" ដូច្នោះដែរ ។

ក្នុងគំនិតនេះ អ្នកនិពន្ធគ្មានប្រយោជន៍អ្វី នឹងការពារឧត្តមគតិឯណាដែលផ្ទុយនឹងប្រយោជន៍ខ្ពង់ខ្ពស់របស់ជាតិផងខ្លួននោះឡើយ ។

គឺ ពីព្រោះតែជាការមួយដែលទាក់ទងដល់អនាគតជាតិ ដល់អនាគតពូជអម្បូរខ្មែរនេះហើយ ដែលអ្នកនិពន្ធអត្ថបទនេះមិនខ្លាចអ្វីនឹងលាតត្រដាងនូវគំនិត ឬយោបល់របស់ខ្លួនដែលជាលទ្ធផលនៃការត្រិះរិះស្រាវជ្រាវរបស់ខ្លួនសុទ្ធសាធ ជូនដល់មតិសាធារណជនជាតិគ្រាន់ជាការពិចារណា។ ឯការពិតសច្ចៈនោះ ស្រេចតែការវិនិច្ឆ័យយល់ឃើញរបស់មតិសាធារណជនជាតិចុះ ។

អ្នកនិពន្ធសៀវភៅដ៏តូចនេះ មានជំនឿយ៉ាងមាំថា ប្រសិនបើការអានសៀវភៅនេះ បណ្ដាលឲ្យមានការពិចារណា ធ្វើការវិនិច្ឆ័យមែននោះ នោះគោលដៅបំណងអ្នកនិពន្ធបានសំរេចហើយ ។ គោលដៅធំរបស់អ្នកនិពន្ធ គឺលើកយកបញ្ហាអនាគតខ្មែរយកមកចោទចំពោះសម្បជញ្ញៈខ្មែរ គឺបង្កើតឲ្យមានជាបញ្ហាឡើងដើម្បីគិត កុំឲ្យភ្លេចខ្លួន ក្នុងឋានៈខ្លួនជាខ្មែររស់នៅលើដែនដីសុវណ្ណភូមិនេះ ។

សូមលោកអ្នកអានមេត្តាអភ័យទោស ប្រសិនបើនៅលើទំព័រទាំងនេះ មានការអធិប្បាយដោយមានលាយតណ្ហាខ្លះ ព្រោះយើងមិនអាចបំភ្លេចឲ្យសូន្យឈឹងនូវមនោសញ្ចេតនារបស់យើង ចំពោះវាសនាជាតិបានឡើយ។ គឺជាការធម្មតាទេ ដែលបេះដូងមនុស្សម្នាក់ស្រពាប់ស្រពោន កាលបើស្រមោលនៃអតីតកាល ដែលជាស្រមោលនៃការឈឺចាប់របស់ជាតិខ្លួន លេចធ្លោមកក្នុងសម្បជញ្ញៈមនុស្សនេះ បូកបញ្ចូលជាមួយនឹងភាពរន្ធត់ញាប់ញ័រនៅចំពោះ មុខអនាគតកាលខ្វះទីដៅ ។

ចំពោះវាសនាខ្មែរក្នុងអនាគត, អ្នកនិពន្ធសៀវភៅដ៏តូចនេះតែងតែចែករំលែកជាមួយផងដែរនូវសេចក្ដីសង្ឃឹម ដែលដូនតាយើងពីព្រេងនាយរមែងបានចិញ្ចឹមទុកក្នុងសន្ដានចិត្តខ្មែរ ។ សេចក្ដីសង្ឃឹមនិងជំនឿនេះ ស្ថិតក្នុងពាក្យស្លោក ឬ ពាក្យទំនាយមួយឃ្លា ដែលដូនតាយើងធ្លាប់បានពោលតៗគ្នាមកថា៖ “ ស្រុកខ្មែរមិនដែលសូន្យ! ”

( Le Pays Khmèr ne périra jamais ! )

ភ្នំពេញ ខែ ធ្នូ ១៩៧០

ន.ឃ.

"Qu'il soit du Nord ou du Sud, il n'est pas un Vietnamien qui ne se sente solidaire du frère dont on l'a arbitrairement séparé, singulier couronnement de l'indépendence recouvrée alors que le « colonialisme » français avait poursuivi le rêve d'hégémonie de l'empereur Gia-Long et que tout son effort avait tendu vers la mise en commun de richesses inégalement réparties mais complémentaires les unes des autres. Comment nourrir la population du Nord-Vietnam sans les réserves alimentaires du Sud et comment mettre en valeur les terrains du Sud sans l'excédent de main d'œuvre du Nord? Pour comprendre le problème, imaginons, une ligne de démarcation qui couperait en France le grenier à blé de la Beauce et les paturages normands, des houillères du Nord et de la métallurgie de l'Est. Pour une superficie de rizières trois fois moindre, le Tonkin a deux fois plus de bouches à nourrir, mais il détient le charbon, le fer, les matières et les sources d'énergie nécessaires à la grande industrie.

Que l'on n'objecte pas les tendances particularistes du Nord et du Sud, maintes fois relevées au cours de l'histoire. Ce serait oublier que l'Allemagne et l'Italie ont connu les mêmes dissensions intérieures et que leur unification aux XIXe siècle a conditionné leur accession au rang de grande puissance.

Le problème se pose dans les mêmes termes pour l'avenir du Vietnam".

André MASSON
in « Histoire du Vietnam »
P.U.F, Paris, 1960



នួន-ឃឿន

# ដំណើរឆ្ពោះទៅទិសខាងលិច
# និង
# ឥណ្ឌូចិនក្នុងឆ្នាំ ២០០០

កើតនៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ១៩៤៤ នៅសៀមរាប-អង្គរវត្ត, លោក **នួន ឃឿន** បានបំពេញវិជ្ជាមធ្យមភូមិនៅវិទ្យាល័យនៃទីរួមខេត្ត រួចទៅបន្តការសិក្សានៅមហាវិទ្យាល័យគរុកោសល្យ និង នៅមហាវិទ្យាល័យអក្សរសាស្ត្រ និង មនុស្សសាស្ត្រនៃសាកលវិទ្យាល័យក្រុងភ្នំពេញទៀត ។ បានប្រឡងជាប់ជាសិស្សសាលាគរុកោសល្យជាន់ខ្ពស់ ( Ecole Normale Supérieure ) ជំនាន់ទី១ ក្នុងឆ្នាំ ១៩៦៥ រួចជាប់បរិញ្ញាប័ត្រខាងប្រវត្តិសាស្ត្រនៅឆ្នាំ ១៩៦៨ ។ សព្វថ្ងៃជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រ ។

ក្នុងពិភពលោកមួយដែលខ្វះសេចក្ដីពិត និងខ្វះស្មេរភាពជាអចិន្ត្រៃយ៍ផងនោះ ស្ថានភាពភូមិ-សាស្ត្រនៃប្រទេសកម្ពុជា ជាប្រទេសមួយតូចរុំព័ទ្ធជុំវិញដោយប្រទេសជិតខាងធំ ៗ មានបណ្ដាជនច្រើនលើសលប់បែបនេះ គឺពិតជាស្ថានភាពមួយប្រកបដោយគ្រោះថ្នាក់ជាក់ស្ដែង ហើយជាការគំរាមកំហែងមួយដ៏សាហាវទៅលើជីវិតនៃប្រទេសយើងទៀតផង ។ អាស្រ័យហេតុនេះ បញ្ហាការគង់វង្សជីវិតនៃរដ្ឋខ្មែរក្នុងភូមិភាគឥតមេត្តានេះ ត្រូវតែជនជាតិខ្មែរម្នាក់ៗចាប់អារម្មណ៍លើសអ្វីៗទាំងអស់ក្នុងឆាកជីវិតរបស់ខ្លួន ។

ដោយបានឃើញច្បាស់នូវមហន្តរាយដែលឃ្លាំចាំប្រល័យជីវិតប្រជាជាតិខ្មែរ លោក **នួន ឃឿន** បានសរសេរអត្ថបទនេះក្នុងបំណងតែមួយ គឺផ្ដល់ការរិះរកឃើញជាគំនិតផ្ទាល់របស់លោកជូនដល់សម្បជញ្ញៈជាតិខ្មែរ ដើម្បីការពិចារណាលើវាសនាមាតុប្រទេសខ្មែរតរៀងទៅ ។

# - សេចក្តីផ្តើម -

តើប្រទេសយៀកណាម នឹងក្លាយទៅជាប្រទេសអាល្លឺម៉ាញឬជប៉ុនទី ២ ក្នុងភូមិភាគអាស៊ីប៉ៃកអគ្នេយ៍ ក្នុងអនាគតនេះឬ?

ក្នុងឋានៈខ្ញុំជាជនជាតិខ្មែរមួយរូប កើតរស់ស្លាប់នៅលើមាតុភូមិខ្មែរ និងក្នុងឋានៈជាអ្នកសិក្សាប្រវត្តិវិទ្យា ខ្ញុំសូមឧទ្ទិសអត្ថបទនេះ ដល់ការភ្ញាក់រឭកនៃសម្បជញ្ញៈនៃជនជាតិខ្មែរ និងដល់សេចក្តីចំរើនលូតលាស់ នៃការយោគយល់រវាងជាតិនិងជាតិដែលជាកត្តាតែមួយគត់ នៃការរួមរស់ដោយសន្តិភាពក្នុងភូមិភាគយើងនេះនៃពិភពលោក ។

តើជនយៀកណាម នឹងក្លាយទៅជាជនជាតិអាល្លឺម៉ង់ក្នុងភូមិភាគអាស៊ីប៉ៃកអគ្នេយ៍ ហើយជាពិសេស ចំពោះកម្ពុជាយើងឬ?

ខ្ញុំពុំអាចនឹងចោទនូវបញ្ហានេះឡើង ដោយខ្វះការឈឺចាប់ខ្លោចផ្សាក្នុងសម្បជញ្ញៈរបស់ខ្ញុំបានឡើយ ។

មនោសញ្ចេតនាលន្លង់លន្លោចស្រងេះស្រងោច ស្តីពុំចេញ តែងតែកើតឡើងក្នុងសម្បជញ្ញៈខ្ញុំ កាលបើយូរៗម្តង ខ្ញុំនឹកគិតទៅដល់បញ្ហាដ៏ធំធេងនិងស្មុគស្មាញនេះ ជាពិសេសគឺបញ្ហានៃការគង់វង្សជីវិតរបស់កម្ពុជាយើង ក្នុងឋានៈជាប្រជាជាតិមួយ (Nation) ក្នុងភូមិភាគអាស៊ីប៉ៃកអគ្នេយ៍នេះ ។ម្យ៉ាងទៀត, នេះជាបញ្ហានៃអនាគតកាល ដែលពិបាកនឹងប្រមើលមើលដោយពិតប្រាកដទុកជាមុន ហើយមួយចំណែកទៀត ប្រវត្តិសាស្ត្រអាចមានករណីលើកលែងដែរ. . . . ។

តែបើទុកជាយ៉ាងដូចម្តេចម្នាក្តី យើងអាចត្រិះរិះបានចំពោះបញ្ហានេះ ដោយអាងទៅលើធម្មតាពនៃប្រវត្តិសាស្ត្រមនុស្សជាតិ ក៏ស្តុតាងប្រវត្តិសាស្ត្រ ដែលកន្លងរួចមកហើយ និងហេតុការណ៍ជាសារវន្តខ្លះៗ ដែលយើងបានឃើញក្នុងឱកាសថ្មីៗ ឬក្នុងបច្ចុប្បន្នកាលនេះ ។ល។

## មេរៀននៃប្រវត្តិសាស្ត្រគឺអ្វី?

*យើងពុំមានបំណងយកទំព័រនេះមកបង្រៀនអំពី* ទស្សនវិជ្ជានៃប្រវត្តិសាស្ត្រ (Philosophie de l'Histoire) *ទេ តែគប្បីយើងធ្វើការរំឭកខ្លះ ដែលមានអត្ថប្រយោជន៍ ចំពោះការយល់របស់យើង យើងត្រូវចៀសវាងនូវ* ការពោលដោយម៉ឺងម៉ាត់ (le dogmatisme) *តែយើងត្រូវតែជា* អ្នកប្រាកដនិយម *។ ទស្សនវិទូជាច្រើនបានចោទសួរចំពោះមេរៀននៃប្រវត្តិសាស្ត្រនេះថា ៖*

តើប្រវត្តិសាស្ត្រមានមេរៀនផ្តល់មកឲ្យយើងទេ? ឬក៏ប្រវត្តិសាស្ត្រមានប្រយោជន៍ទេ? *។ បើស្រេចទៅតាមលោក* ហ៊ែហ្គែល **(Hegel)** *ឬ* ប៉ូល វ៉ាឡេរី **(Paul Valéry)** *ប្រវត្តិសាស្ត្រអាចមានឬគ្មានប្រយោជន៍អ្វីទាល់តែសោះ។ ចំពោះយើង យើងយល់ថាប្រវត្តិសាស្ត្រមានប្រយោជន៍ផង ហើយគ្មានប្រយោជន៍ផង ប្រវត្តិសាស្ត្រដែលគ្មានប្រយោជន៍ ដែលហ៊ានអះអាងយ៉ាងនេះ គឺដោយហេតុថា គ្មានបាតុភូតព្រឹត្តិការណ៍ប្រវត្តិសាស្ត្រឯណា* (Phènomènes ou évènements historiques) *អាចកើតឡើងវិញពីរដង ហើយមានលក្ខណ៍ដូចគ្នាឡើយ* (Les évènements historiques ne se répètent pas, ou tout du moins de la même façon) ។

*ការពន្យល់នេះ អាស្រ័យដោយហេតុថា ក្នុងសម័យមួយ មានស្ថានភាព ឬលក្ខន្តិកៈ* **(Conditions)** *សង្គមកិច្ចនយោបាយ វប្បធម៌សេដ្ឋកិច្ច. . . . ប្លែកពីសម័យមួយទៀត ។ ដូច្នេះហើយ យើងពុំអាចរកពីស្ថានភាពពីរ ឲ្យមានលក្ខណៈដូចគ្នាបានទេយ៉ាងណាមិញ យើងក៏ពុំអាចទាញនូវមេរៀនអ្វីមួយឲ្យប្រាកដប្រជាអាចយកអ្វីជាគំរូបានឡើយ ។*

*គួរយើងយកឧទាហរណ៍មកពន្យល់ :*

*សង្គ្រាមលោកលើកទី១ ទុកណាជាទម្លាក់ការខុសត្រូវដ៏ធ្ងន់ទៅប្រទេសអាល្លឺម៉ាញក្តី ក៏មូលហេតុដែលបណ្តាលនេះស្មុគស្មាញណាស់ មិនមែនតែប្រទេសអាល្លឺម៉ាញម្នាក់ឯងទេ គឺទ្វីបអឺរ៉ុបនេះឯងជាអ្នកទទួលខុសត្រូវ, ដោយបង្កើតឲ្យមាននូវការប្រណាំងប្រជែង* (Rivalités) *ខាងផ្លូវសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម, ហើយចុង*

ក្រោយបង្អស់ ការប្រណាំងប្រជែងផ្លូវនយោបាយទូតនិងយោធា ហើយទាំងអស់ក៏ជាផលវិបាកនៃការលូតលាស់ឬវិវឌ្ឍន៍ នៃរបបមូលធនអន្តរជាតិដែរ (développement du capitalisme International) ។ ដល់សង្គ្រាមលោកលើកទីពីរផ្ទុះឡើង ពិភពលោកហាក់ដូចជាយល់ថា ប្រវត្តិសាស្ត្រថយក្រោយវិញច្រំដែល (se répéter) ។

ប្រទេសអាល្លឺម៉ាញបង្កសង្គ្រាមលោកទៀតហើយ តែបើតាមការពិតទៅ, សង្គ្រាមលោកលើកទីពីរនេះ គឺបណ្ដាលមួយភាគធំអំពីការឆ្កួតលីលា (la folie) នៃមនុស្សម្នាក់ គឺ ហ៊ីត្លែ (Hitler) នេះឯង ។ រីឯសង្គមអាល្លឺម៉ង់វិញ ពីសម័យ ហ្គីយោមទី២ (Guillaume II) មកសម័យ ហ៊ីត្លែរ គឺមានការប្រែប្រួលច្រើនណាស់ទៅហើយ។ ឯចំណែកស្ថានការណ៍អន្តរជាតិផ្នែកសេដ្ឋកិច្ចនយោបាយ វិទ្យាសាស្ត្រក៏ដូច្នោះដែរ ។

តើទាំងនេះឬ ដែលគេសន្និដ្ឋានថាប្រវត្តិសាស្ត្រគ្មានប្រយោជន៍? នេះគឺជាមតិ ឬជានិក្ខេបបទ(Thèse) មួយដែរ។ តែបើយើងពិចារណាឲ្យជ្រៅជ្រះដោយយកធម្មភាគនៃការវិវឌ្ឍន៍នេះជាទីអាង, យើងពុំអាចកាត់ផ្ដាច់ប្រវត្តិសាស្ត្រជាកង់ដុំៗ(Morceaux)ចេញពីគ្នាឡើយ ។ បច្ចុប្បន្នកាលយើងនេះជាលទ្ធផលនៃអតីតកាលសម័យបុរាណ។ល។ ហើយគេថយទៅក្រោយរហូតទៅដល់កំណើតនៃពិភពលោក. . . ។ ជាការពិតណាស់ វត្ថុក្នុងលោកនេះ អ្វីៗក៏ដោយមានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធ (Tout est lié à tout) ។ យ៉ាងណាមិញ យើងពុំអាចផ្ដាច់អតីតកាលថ្មីៗ ឬបុរាណនិងបច្ចុប្បន្នកាល និងអនាគតកាលបានឡើយ ។ ដូច្នេះ ប្រវត្តិសាស្ត្រប្រាកដជាពន្លឺបញ្ចាំងមកលើបច្ចុប្បន្នកាលនិងអនាគតកាល ។

គឺក្នុងន័យនេះហើយ ដែលយើងគួរលើកយកបញ្ហាដើមរបស់យើងមកដោះស្រាយ គឺបញ្ហានៃការគង់វង្សជីវិតប្រជាជាតិយើងក្នុងភូមិភាគនេះនៃពិភពលោក, បំភ្លឺដល់សម្បជញ្ញៈយើងរាល់គ្នា។

x

x x

# ប្រទេសយៀកណាមនិងយើងក្នុងអតីតកាល

ក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ មានចលនា ទេសន្តរប្រវេសន៍ **(Migration)** មួយដែលមានលក្ខណៈជាទូទៅ ហើយគេសង្កេតមានមកហើយ ក្នុងសម័យអតីតកាលបូរាណ និងថ្មីៗនេះ គឺ "ដំណើរទៅទិសខាងត្បូង" (La marche vers le sud) នៃជនជាតិទាំងឡាយ ដែលរស់នៅផ្នែកខាងជើងនៃផែនដី (Hémisphère Nord) ។

ដូចនេះ នៅទ្វីបអឺរុប ជនខាងជើងដូច ន័រម៉ង់ (Normands) ហ្សែរម៉ានីក (Germaniques) បានរុញច្រានចុះមកខាងក្រោម ចាប់តាំងពីសតវត្សទី៥-៦ រហូតមកដល់សតវត្សទី១១-១២ ។ នៅទ្វីបឥណ្ឌា ជនជាតិ អារយិន (Aryens) សម្បុរស បានចុះមកពីប៉ែកខាងត្បូងនៃប្រទេសរុស្ស៊ី មកតាំងនៅខាងត្បូងនៃជួរ ភ្នំហិមពាន្ត ក្នុងទីវាល នៃ ទន្លេសិន្ធុ និង ទន្លេគង្គា (Plaine indo gangetique) ហើយរុញច្រានជាតិ ឥណ្ឌា ដើមសម្បុរខ្មៅ (Les dravidiens) ឲ្យចុះមកនៅផ្នែកខាងត្បូង (Le Dekkan) ។

នៅខាងជើង និងខាងលិចនៃប្រទេស **កម្ពុជា** ជនជាតិសៀម ដែលមានកំណើតនៅក្នុងអាណាខេត្ត យូណាន (Yunnan) នៃប្រទេសចិន, បានចាប់ផ្តើមសម្រុកចុះមកខាងត្បូង តាំងពីសតវត្សទី១២ មកម៉្លេះ ដោយបានមកតាំងនៅក្នុងអាណាខេត្តខ្មែរទាំងឡាយ ខាងលិចប្រទេស **កម្ពុជា** សម័យបច្ចុប្បន្ន ហើយរុញច្រានរហូតដល់ទៅម៉ាឡាយូ រួចតាំងទីនៅលើខេត្ត ម៉ាឡាយូ នេះផងៗ ក្នុងឧបទ្វីប **សិណ្ហចិន** ដដែលនេះ ជនជាតិ យៀកណាម ដែលមានដើមកំណើត នៅភូមិភាគ **តុងកឹង** (Tonkin) ក៏បានធ្វើការសម្រុកចុះមកក្រោមដែរ៖ មកដល់ចុងសតវត្សទី១៤ ជនជាតិយៀកណាម បានវាយដណ្តើមហើយតាំងទីរបស់ខ្លួនក្នុងអាណាខេត្តខាងជើងទាំងឡាយ នៃនគរ **ចាម** (Champa) មានខេត្ត ក្វាងប៊ីញ (Quang Binh) ក្វាងទ្រី (Quang Try) ហ៊ើ (Hué) ហើយរហូតមកដល់ ទូរ៉ាន (Tourane) សព្វថ្ងៃ ។ ពីសតវត្សទី១៥ មកដល់សតវត្សទី១៧ នគរ **ចាម** ទាំងមូល រហូតមកដល់ ប៊ីញថាញ់ (Binh Thuan) ប៉ែកខាងត្បូងបំផុត ត្រូវរលាយបាត់ឈ្មោះពីផែនទីនៃពិភពលោក (១៦៩៦) ។

ការវាតទីតាំងនៅក្នុងនគរ **ចម្ប៉ា** មិនទាន់ទាំងចប់ស្រេចបាច់ហើយផង, និគមជន “ **យួន** ” ក៏ចាប់ផ្ដើមរុលសំរុកចុះមកក្រោមទៀត ដើម្បីមកដល់ទល់ដែន **កម្ពុជាក្រោម** តែម្ដង ។ ដែនដីដ៏មានជីជាតិ សម្បូណ៌ទៅដោយធនធានខាងកសិកម្ម មានស្រូវ ត្រី និងដំណាំគ្រប់បែបយ៉ាងនៅដែនដីសណ្ដ (Delta) នៃទន្លេមេគង្គ និងបណ្ដាជនជាតិខ្មែរដែលមានចំនួនតិចនៅឡើយ (តាមស្ថិតិដែលមាននាចុងសតវត្សទី ១៧ មានជនជាតិខ្មែរប្រហែល ៤០, ០០០ គ្រួសារ គឺប្រហែល ២០០ ០០០ នាក់ តែប៉ុណ្ណោះ លើផ្ទៃដីជាង ៦០, ០០០ គម២)[១] ហេតុទាំងនេះឯង បានទាក់ទាញអារម្មណ៍ដល់អាណានិគមយួនជាខ្លាំង ដែលជាច្រើនសតវត្សមកហើយ បានឃ្លាតកាន់តែឆ្ងាយទៅអំពីដែនដីសណ្ដនៃទន្លេក្រហម (Delta du Fleuve Rouge) ជាភូមិភាគកំណើតរបស់ខ្លួន ប្រកបដោយធនធានកសិកម្ម ដូចជាដែនដីសណ្ដទន្លេមេគង្គដែរ ។

អាស្រ័យហេតុនេះហើយ គោលបំណងយកភូមិភាគខាងត្បូងនៃកម្ពុជា ត្រូវចាត់ជាគំរោងការដែលត្រូវអនុវត្តភ្លាមៗ នៃជនជាតិវៀតណាម ចាប់តាំងពីសតវត្សទី ១៧ មកម៉្លេះ។ នៅដើមសតវត្សទី១៧ គេក៏ចាប់ផ្ដើមចូលមកតាំងនៅដោយស្ងៀមស្ងាត់ជាធម្មតា ក្នុងចំណោមអាណាខេត្តខ្មែរ ប៉ែកខាងកើតនៃដែនដី កម្ពុជាក្រោម គឺភូមិភាគបារៀ (Baria) បៀនហ្វា (Bien Hoa) , ព្រៃនគរ សព្វថ្ងៃនេះ។ ការតាំងទីនេះ ធ្វើទៅបានក៏ដោយសារតែការធ្វេសប្រហែស នៃរាជការខ្មែរយើងក្នុងខេត្តទាំងឡាយនោះ, ហើយអាស្រ័យម្យ៉ាងទៀត មកអំពីសង្គ្រាមក្នុងស្រុករវាងគ្នាឯង ក្នុងការវិវាទដណ្ដើមបល្ល័ង្ករាជ្យនៃក្សត្រខ្មែរ។ ក្នុងឆ្នាំ ១៦៥១ ជនជាតិខ្មែរបានទៅសូមជំនួយអំពីស្ដេច ង្វៀង វឿង (Hien Vuong) ដើម្បីទប់ទល់នឹងក្សត្រដណ្ដើមរាជ្យមួយអង្គ ។ ង្វៀង វឿង ក៏ប្រញាប់ប្រញាល់បញ្ជូនកងទ័ពមួយពលធំទៅជួយ ហើយឆ្លៀតឱកាសនោះ ធ្វើការបង្ខំដណ្ដើមយកអាណាខេត្តបារៀ និងបៀនហ្វាតែម្ដងទៅ ទុកជាសគុណនៃជំនួយនោះ។ នយោបាយអន្តោគមន៍ផ្ទៃក្នុងនៃជនជាតិយួន ចេះតែមានបន្តទៅទៀតស្របតាមចលាចលដែលមានញយៗ ក្នុងប្រទេស **កម្ពុជា** ។ ហេតុនេះហើយ ក្នុងឆ្នាំ ១៦៨៦ អាណាខេត្តព្រៃ

---

(១) យោងទៅតាមសៀវភៅរបស់ (Lê Thánh Khôi, Le Viet-Nam, Editions de Minuit, Paris, 1955.)

នគរ *កំត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃជនជាតិយួន ហើយមកដល់ដើមសតវត្សទី១៨ ការវាតទីតាំងនេះ បានមកដល់ទន្លេមេគង្គជាស្រេចៗ នាដើមសតវត្សទី១៨ ដោយសំអាងទៅលើកិច្ចការពាររបស់ខ្លួនប្រឆាំងនឹងសៀម ទៅលើអាណាខេត្តខ្មែរប៉ែកខាងលិច នៃកម្ពុជាក្រោម ខេត្ត* ពាម (Ha Tien) រាជា (Rach Gia) *សព្វថ្ងៃនេះ ជនជាតិយួនក៏មកធ្វើអន្តរាគមន៍ថ្មីទៀត ទៅលើខេត្តទាំងនោះ ។ ឆ្នាំ ១៧៣៩ ព្រះមហាក្សត្រខ្មែរទ្រង់បានធ្វើសង្គ្រាមយកខេត្តពាមមកវិញ តែពុំបានសម្រេចដូចបំណង ។ តពីនេះទៅ អាណាខេត្តប៉ែកកណ្ដាលនៃកម្ពុជាក្រោម មានខេត្ត* មេស (My Tho) វិញឡុង (Vinh Long) *(១៧៣១)* ផ្សារដែក (Sa Dec) *និង* មាត់ជ្រូក (Chau Doc) *(១៧៥៧) ក៏របេះពីមាតុភូមិខ្មែរម្ដងមួយៗ ធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃជនជាតិយួន, អាណានិគមពង្រីកទឹកដី ថ្វីបើមានការតវ៉ា និងតស៊ូអំពីរាជបល្ល័ង្កក្រុងឧត្តុង្គក៏ដោយ ។ នាឆ្នាំ ១៧៦៥ ដែនដីកម្ពុជាក្រោមទាំងមូលធ្លាក់ទៅជាដែនដីអាណានិគមយួន លើកលែងតែខេត្តទ្រាំង* (Soc Trang) *និង ជ្រោយទឹកខ្មៅ* (Camau) *ដែលទាល់តែជិតមួយសតវត្សទៀត គឺឆ្នាំ ១៨៤០ ទើបធ្លាក់ទៅក្នុងអំណាចយួនជាដាច់ស្រេច ។*

*. . . ពីពេលនោះមក ប្រវត្តិសាស្ត្រនៃ* កម្ពុជាក្រោម *ដូចជាប្រវត្តិសាស្ត្រនៃ* នគរចម្ប៉ា *ដែរ ក៏រលាយចូលជាមួយនឹងប្រវត្តិសាស្ត្រនៃប្រជាជាតិវៀតណាមរហូតមកទល់ថ្ងៃនេះ ។*

x

x x

# អាណានិគមនិយមទាំង៣ ប៉ះទង្គិចគ្នានៅឥណ្ឌូចិន

ការដែលយើងយកអតីតកាលដ៏ជូរចត់នេះ មករំឭកក្នុងទីនេះធ្វើយនឹងគោលបំណងមួយច្បាស់លាស់ណាស់ គឺដើម្បីបំភ្លឺដល់ការវិវឌ្ឍន៍នៃប្រវត្តិសាស្ត្រក្នុងភូមិភាគនៃពិភពនេះតែប៉ុណ្ណោះ គ្រាន់ជាពន្លឺដល់សម្បជញ្ញៈ នៃយើងរាល់គ្នា។ ការវិនិច្ឆ័យឲ្យតម្លៃឬដាក់ទោស ទៅលើជនណាម្នាក់ ប្រជាជាតិណាមួយ ឬផ្ទុយទៅវិញ ការសរសេរក្តី ឬការញុំាងឲ្យមានការស្អប់ខ្ពើម រវាងជាតិមួយនិងជាតិមួយទៀត... ទាំងអស់នេះមិនមែនជាគោលដៅនៃប្រវត្តិវិទូទេ។ ដូចនេះ ការរំឭកជាការចាំបាច់ខាងផ្លូវបញ្ញា (Besoins de l'intelligence) ដើម្បីពន្យល់តែប៉ុណ្ណោះ ។

តាំងពីដើមរៀងមក អាណានិគមនិយមនិងការពង្រីកទឹកដីនិយម នៃ សៀម ហើយនិង យួន ជាការគំរាមកំហែងដ៏គ្រោះថ្នាក់បំផុត ដល់អាយុជីវិតនៃប្រទេស កម្ពុជា និង លាវ ។ មុនការមកដល់នៃជនជាតិស្បែកសក្នុងភូមិភាគនេះ នៅដើមសតវត្សទី ១៩ កម្ពុជា និង លាវ ស្ទើរតែស្គាល់នូវវាសនាអកុសលនៃ ចម្ប៉ា និងប្រទេសដ៏ច្រើនទៀតនៃពិភពលោកទៅហើយ។ តែពេលនោះ ប្រវត្តិសាស្ត្រហាក់ដូចជាដើរលឿន, ស្របទៅតាមល្បឿននៃប្រវត្តិសាស្ត្រ និងបច្ចេកទេសនៃបច្ចិមប្រទេស។

ក្នុងរាជ្យព្រះបាទ មិញ ម៉ាង (Minh Mang) (១៨២០-១៨៤១) ប្រទេសកម្ពុជាទាំងមូលត្រូវបែងចែកជាពីរភាគ ដែលមានទល់ដែននៅត្រង់ខ្សែបន្ទាត់ខ័ណ្ឌខេត្តពោធិសាត់និងបាត់ដំបង ហើយខ្សែនេះឆ្លងបឹងទន្លេសាបឡើងទៅដល់មង្គលបូរី ... មុននឹងតម្រង់ឆ្ពោះទៅស៊ឹងត្រែង ទៅដល់ព្រំប្រទេសខ្មែរ-វៀតណាមសព្វថ្ងៃនេះ។ ដូចនេះ ដី១ភាគ៣ នៃកម្ពុជាភាគខាងជើងទន្លេសាបក្លាយទៅជាអាណាខេត្តសៀម។ ២ភាគ៣ នៃផែនដីខ្មែរ ក្រោមខ្សែបន្ទាត់ដដែលនោះក្លាយទៅជាអាណាខេត្តយួន ឈ្មោះ ត្រាន តាយ ថាញ់ (Tran Tay Thanh) ដែលមានមេទ័ព ទ្រឿង មិញ យ៉ាង (Truong Minh Giang) ជាស្តេចត្រាញ់មានធានីនៅ ណាំយ៉ាង (ភ្នំពេញ) ។

នេះប្រាកដជា ដំណើរឆ្ពោះមកទិសខាងលិច វិញ ដោយហេតុ ដំណើរសំរុកចុះមកក្រោម បានសម្រេចដល់គោលដៅ ព្រោះដោយ ទឹកខ្មៅ (Camau) ជាដែនដីខាងត្បូងបំផុតនៃ

ឥណ្ឌូចិន បានត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃយួនរួចទៅហើយ។ តែអាណាខេត្រថ្មី ត្រាន តាយ ថាញ់ នេះពុំមានអាយុយឺនយូរទេ ព្រោះការអនុវត្តន៍នយោបាយតឹងរ៉ឹង បញ្ចូលខ្មែរឲ្យទៅជាយួន (politique d'assimilation forcée) បណ្ដាលឲ្យមានប្រតិកម្មយ៉ាងខ្លាំងពីសំណាក់មហាជនខ្មែរ។ ការបះបោរប្រឆាំងបំបាត់យួនជិះជាន់ដឹកនាំដោយ ព្រះអង្គដួង ដោយមានជំនួយសៀមផង បានធ្វើឲ្យអំណាចយួនមានការខូចខាតយ៉ាងច្រើន ហើយ ទ្រឿង មិញ យ៉ាង ក៏ដកខ្លួនថយទៅនៅ អាន យ៉ាង ក្នុងឆ្នាំ ១៨៤១ ។ នយោបាយធ្វើ ខ្មែរ ឲ្យទៅជា យួន ក៏ត្រូវទទួលបរាជ័យយ៉ាងជាក់ស្ដែង ។ ជាមួយគ្នានេះ ការមកដល់នៃពួកបារាំងចាប់ពីឆ្នាំ ១៨៥៨ ទៅ, នៅដែនដីកូសាំងស៊ីនបានបើកយុគថ្មីមួយទៀត ក្នុងប្រវត្តិសាស្ត្រនៃឥណ្ឌូចិន។ អាណានិគមនិយមយួន ក៏ត្រូវឈប់ស្ទះមួយអន្ទើសិន....,
ព្រោះប្រទេសយួនខ្លួនឯង ត្រូវក្លាយទៅជាដែនដីអាណានិគមបារាំងម្ដងវិញ ។

ចំណែកឯភូមិភាគសៀមនៃ កម្ពុជា មានបាត់ដំបង សៀមរាប ម្លូព្រៃ ទន្លេរពៅ និងស្ទឹងត្រែង សៀមត្រួតត្រាហូតដល់ឆ្នាំ ១៩០៧ ទើបប្រគល់មកឲ្យខ្មែរវិញ ដោយសារការសង្កត់សង្កិនខាងផ្លូវទូតនិងផ្លូវយោធានៃប្រទេសបារាំងអាណានិគម ដែលប្ដូរដែនដីទាំងនោះជាមួយនឹងខេត្រត្រាតនិងចន្ទុតាប៊ុន ជាអាណាខេត្រសៀម ទល់មុខនឹងខេត្រកោះកុងបច្ចុប្បន្ននេះ ។

ចំពោះឯលាវវិញ ក៏ស្ថានការណ៍មិនខុសពីកម្ពុជាដែរ ។ ពីទល់ដែនចិនមកដល់ខ្មែរ ប្រទេសលាវត្រូវបែងចែកនៅដើមសតវត្សទី១៩ ទៅជាអាណាខេត្តសៀម និងយួន ហើយនៅសល់តែរាជាណាចក្រតូច នៃ ហ្លួងព្រះបាង និង ចំប៉ាសាក់ ដែលនៅរង់ចាំការបែងចែកបន្តទៅទៀតប៉ុណ្ណោះ ។ ក៏ប៉ុន្តែដូច កម្ពុជា ដែរ ការមកដល់នៃអាណានិគមនិយមបារាំងបានស្រោចស្រង់ លាវ ឲ្យផុតពីមហន្តរាយ. . . ។

នេះជាការពិត, អាណានិគមនិយមបារាំង គឺជាហ្វ្រាំងដ៏សក្ដិសិទ្ធិ ទប់អាណានិគម ពង្រីកទឹកដីសៀមនិងយួននៅសតវត្សទី១៩ មិនឲ្យលេបដែនដីខ្មែរនិងលាវតទៅទៀតបាន ។

x

x x

# ឯណាគ្រោះថ្នាក់ ?

*តើគ្រោះថ្នាក់យើងនៅឯណា ? យួនឬសៀម ? តើប្រទេសសៀមជាមហាគ្រោះថ្នាក់ដល់អនាគតនៃ កម្ពុជា មែនឬ ? ប្រទេសសៀមសម័យបច្ចុប្បន្ននេះ ជាប្រជាជាតិមួយធំ ( ជាង ៣០ លាននាក់ ) ដែលមានទីតាំងនៅកណ្ដាលនៃឧបទ្វីបអាស៊ីអគ្នេយ៍ដីគោក លើដែនដីមួយដែលមានទន្លេមេណាម (= មេទឹក) ហូរកាត់ជាកណ្ដាល ហើយដែលប្រកបទៅដោយដីជាតិ ហើយនិងធនធានកសិកម្មយ៉ាងធំធេង ។ ទីតាំងនៅកណ្ដាលយ៉ាងនេះ នៃប្រទេសសៀមលើវាលទំនាបស្ដុកស្ដម្ភ* (au milieu d'une plaine riche) *អាចផ្ដល់ឲ្យប្រទេសសៀមនូវនាទីមួយយ៉ាងធំ ក្នុងភូមិភាគនេះនៃពិភពលោក ។ តែការពិត ហាក់ដូចមិនដូច្នេះសោះ ។ ប្រទេសសៀមមានលក្ខណៈជាដែនដី មួយដែលមានការលាតសន្ធឹងជាអតិបរមាទៅហើយ ពីខាងជើង គឺទល់ដែនសៀម លាវ-ភូមា មកដល់ខាងត្បូងទល់ដែនសៀម-ម៉ាឡាយូ មានចម្ងាយប្រហែល ២០០០ គីឡូម៉ែត្រ ហើយប្រទេសនេះខ្វះឯកភាពខាងភូមិសាស្ត្រ* (absence de l'unité géographique) *នយោបាយនិងសេដ្ឋកិច្ចផង ។ ភូមិភាគប្រកបដោយធនធានគឺដីសណ្ដនៃទន្លេមេណាម ដែលមានបណ្ដោយប្រហែល ៤៦០ គ.ម. និងទទឹង ២០០ គ.ម. ។ ដីនេះ គឺជាជង្រុកស្រូវនៃប្រទេសសៀម, ជាបេះដូងសេដ្ឋកិច្ចជាតិ ។*

*ភូមិភាគផ្សេងពីនេះ ជាភូមិភាគបន្ទាប់បន្សំ ចំពោះជនជាតិសៀមហើយអ្នកដែលរស់នៅនោះ មិនមែនជាជនជាតិសៀមសុទ្ធសាធផង- តំបន់ខាងជើង គឺពួកជនជាតិភាគតិច* ការេន, ចាម, លាវ *ខាងជើងឆៀងខាងកើត គឺ* លាវ *និង* ខ្មែរ *ខាងត្បូងឆៀងខាងកើត គឺ* ខ្មែរ យួន និង ចិន *ឯខាងត្បូងមានជនជាតិ* ម៉ាឡាយូ *កាន់សាសនាឥស្លាម ។ ជនជាតិបរទេសទាំងនេះដែលរស់នៅជុំវិញទន្លេមេណាម មានការអាក់អន់ចិត្តជាខ្លាំង ដោយជនជាតិសៀមទុកពួកទាំងនេះ ជា "ពលរដ្ឋបន្ទាប់បន្សំ* (Citoyens de second zone) *" ហើយការលូតលាស់ខាងសេដ្ឋកិច្ចទៀតសោត ក៏ឃើតយូរថយថោកជាច្រើន បើប្រៀបធៀបនឹងភូមិភាគក្រុងបាងកក និងតាមដៃទន្លេមេណាម ដែលជនជាតិសៀម និងចិនរស់នៅដោយកកកុញ ។ ហេតុការណ៍ទាំងនោះបណ្ដាលឲ្យមានចលនាអ្នកជាតិនិយម* (Mouvements Séparatistes) *នៅតាមដែនដីទាំងនោះ ជាគ្រោះថ្នាក់មួយយ៉ាងធំចំពោះឯកភាពខាងនយោបាយនៃប្រទេស ។*

បញ្ហាធំ ដែលចោទសព្វថ្ងៃ គឺការកើនដ៏ឆាប់រហ័ស (une démographie galopante) នៃជនជាតិសៀម ។ ដែនដីសណ្តនៃទន្លេមេណាមនឹងពុំអាចទប់ទល់ដល់ទម្ងន់ដ៏កាន់តែធ្ងន់ឡើងៗនេះទេ ។ ដូច្នេះ ដើម្បីដោះស្រាយបញ្ហានេះ គេត្រូវពង្រីកនូវធនធានកសិកម្ម ឯដីដែលនៅជុំវិញដែនដីសណ្ត ជាដីក្រទាំងអស់ ។ នេះហើយដែលធ្វើឲ្យជនជាតិសៀមនឹកគិតទៅដល់ទីវាលទំនាបនៃទន្លេមេគង្គ និងទន្លេសាបមានខេត្របាត់ដំបងខ្មែរជាដើម ដែលសម្បូរទៅដោយធនធានកសិកម្ម អាចចិញ្ចឹមមនុស្សច្រើនលាននាក់ ។ ថ្វីបើសម័យបច្ចុប្បន្ននេះ គម្រោងផែនការនេះហាក់ដូចអនុវត្តមិនសម្រេចដោយហេតុថា សៀមមានបញ្ហាផ្ទៃក្នុង. . . ក៏ប៉ុន្តែទៅអនាគតទេ បើសេដ្ឋកិច្ចសៀមមិនបានលូតលាស់ឲ្យស្របទៅតាមការកើនយ៉ាងឆាប់រហ័សនៃបណ្តាជនទេ ការវាយដណ្តើមយកប៉ែកខាងលិចនៃប្រទេសកម្ពុជា អាចទៅជាការពិតបាន ។

នេះស្រេចទៅលើការវិវឌ្ឍន៍នៃប្រវត្តិសាស្ត្រ ។ ក្នុងបច្ចុប្បន្ននេះ សៀមនៅទន់ខ្សោយខាងផ្ទៃក្នុង ពុំអាចលាតសន្ធឹងបានទៀតទេ បើមិនដូច្នោះទេ ឯកភាពសៀមច្បាស់ជាត្រូវទទួលការគំរាមកំហែង ពីជនជាតិភាគតិចយ៉ាងធ្ងន់ធ្ងរមិនលែងឡើយ ។ ការលាតសន្ធឹងហួសមាឌ នឹងនាំមកឲ្យសៀមនូវភាពទន់ខ្សោយវិញទេ ។ អាស្រ័យហេតុនេះហើយ បើតាមយោបល់របស់យើង គ្រោះថ្នាក់របស់យើងមិនមែននៅទិសខាងលិច គឺខាងកើតជាប្រាកដ ។

## ប្រទេសយៀកណាមរួបរួមគ្នា... គ្រោះថ្នាក់ដល់កម្ពុជា !

បើប្រទេសយៀកណាមខាងជើង និងខាងត្បូងរួបរួមគ្នាវិញ ប្រទេសនេះនឹងទៅជាប្រទេសជាតិយ៉ាងធំនៃអាស៊ីភាគអគ្នេយ៍ (៤០ លាននាក់) ។

បើប្រសិនណាជាចំនួនបណ្តាជនជាកត្តាមួយបន្ទាប់បន្សំ ចំពោះមហិទ្ធិរិទ្ធនយោបាយ (la puissance politique) នៃរដ្ឋនីមួយៗ គុណសម្បត្តិនៃប្រជារាស្ត្រ (les qualités d'un peuple) និងការវិវឌ្ឍន៍នៃបណ្តាជន (L'évolution de la population) ប្រាកដជាកត្តាដែលសំខាន់ជាងគេបំផុត ។ ចំណែកឯកត្តាទាំង៣នេះ ជនជាតិវៀតណាមមានទាំងអស់ ដោយឥតប្រកែកបាន -ទី១ បណ្តាជនច្រើនអាចលេបឥណ្ឌូចិនទៅអនាគតបាន, ទី២ ការកើនដ៏លឿនរហ័សនៃបណ្តាជននេះ, និងទី៣ សំខាន់បំផុតគឺគុណសម្បត្តិជាពិសេសនៃប្រជារាស្ត្រវៀតណាមនេះឯង ។ ចំពោះករណីខាងក្រោយនេះ បើមានជនជាតិឯណា ដែលគេអាចប្រដូចបានជាមួយនឹងជនជាតិយួន គឺជនជាតិជប៉ុននិងអាល្លឺ-ម៉ង់នេះឯង ។ ជនជាតិយៀកណាម ជាប្រជារាស្ត្រមួយប្រកបដោយប្រាជ្ញាថាមពល

សេចក្តីក្លាហាននិងពិសេសបំផុតចិត្តតស៊ូ ។ល។ ប្រវត្តិសាស្ត្រនៃជនជាតិយៀកណាមនេះ ជាប្រវត្តិសាស្ត្រនៃសង្គ្រាមដែលប្រជារាស្ត្រយៀកណាមបានធ្វើដោយឥតស្រាកស្រាន្តជាមួយនឹងបរទេសនៅជិតខាង មាន ចិន ចម្ប៉ា លាវ សៀម ខ្មែរនិងវាងគ្នានិងគ្នាខាងជើងទល់នឹងខាងត្បូង ។ ការនេះកើតមានឡើងជាច្រើនសតវត្សមកហើយ ហើយហាក់ដូចជាគ្មានសញ្ញាឯណាបញ្ជាក់ថា សង្គ្រាមនេះនឹងឈប់ស្ងេះហើយ ទោះជាក្រោយការបញ្ឈប់សង្គ្រាមនៅយៀកណាមសព្វថ្ងៃនេះក្តី ។ វាសនានៃប្រទេសយៀកណាមជាវាសនានៃប្រជាជាតិមួយដែលពង្រីកទឹកដីដោយសង្គ្រាម ហើយដែលត្រូវគេធ្វើសង្គ្រាមទៅអនាគតទៀត ។ សង្គ្រាមញឹកញយយ៉ាងនេះ បានសម្រេចធ្វើឲ្យជនជាតិយៀកណាមមានចរិតរឹងប៉ឹង ចេះអត់ធ្មត់សេចក្តីលំបាក មានការតស៊ូដោយស្វិតស្វាញ គឺលក្ខណៈទាំងនេះឯង ដែលជាភាពអនុគ្រោះដល់ការប្រយុទ្ធដោយវិធីហិង្សា ។ នេះជាកត្តាខាងផ្លូវចិត្តសាស្ត្រ ដែលសារៈសំខាន់ចំពោះការយល់របស់យើង ។

ចូរយើងនឹកគិតទៅដល់ប្រវត្តិសាស្ត្រ តើជនប្រភេទណាដែលមកវាតទីតាំងនៅចម្ប៉ា និងនៅ កម្ពុជាក្រោម? គឺជនអានាថាក្រលំបាកតោកយ៉ាក អ្នកទោសដែលគេដេញពីប៉ែកខាងលើ ឲ្យចុះមករកទីតាំងដីថ្មីនៅភូមិភាគខាងក្រោម អ្នកទាំងនេះមកជាទាហានផង ជានិគមជន (Colons) ផង ។

មុនដំបូងមកតាំងនៅដោយស្ងៀមស្ងាត់ រួចហើយក៏តាំងបង្ករឿងហេតុទាល់តែម្ចាស់ដីដកខ្លួនចេញពីទីនោះទៅ...។ ឥឡូវនេះព្រឹត្តិការណ៍នេះចាប់មានជាថ្មីឡើងវិញហើយ សព្វថ្ងៃនេះនៅកម្ពុជាយើង, យ៉ាងនេះគួរតែយើងមានបុព្វហេតុនៃសេចក្តីព្រួយបារម្ភរបស់យើង[១] ។

(១)-អត្ថបទនេះសរសេរក្នុងឆ្នាំ១៩៦៩ គឺមុនអន្តរាគមន៍នៃកងទ័ពយៀកណាមខាងត្បូងក្នុងប្រទេសកម្ពុជាក្រោយថ្ងៃទី១៨មីនា១៩៧០

# អាណានិគមនិយមពង្រីកទឹកដី ឬ អាណានិគមនិយមសេដ្ឋកិច្ច

**( Colonialisme territorial ou Colonialisme économique ? )**

*ការឈ្លានពានវាយដណ្តើមយកទឹកដី ដោយកម្លាំងទ័ពក្នុងសម័យសតវត្សទី ២០ នេះ ហាក់ដូចជាហួសសម័យនិយមទៅហើយ ។ នាបច្ចុប្បន្នកាលនេះ ស្ថាប័នជាច្រើននៃមនុស្សជាតិ មានអង្គការសហប្រជាជាតិ, មតិសាធារណជនអន្តរជាតិ អង្គការការពារសន្តិភាព នយោបាយសម្ពន្ធមិត្ត ។ល។ សុទ្ធសឹងតែជាកម្លាំងខាងផ្លូវចិត្ត ជាឧបសគ្គដល់ការរំលោភដណ្តើមយកទឹកដីដោយស្រួល អំពីសំណាក់ជាតិមួយ ទៅលើជាតិមួយទៀត ។*

*ក៏ប៉ុន្តែអាណានិគមនិយមសម័យថ្មី ដែលយើងគួរបារម្ភ គឺអាណានិគមតាមរយៈសេដ្ឋកិច្ច ។ យៀកណាមខាងជើង ប្រកបដោយឧស្សាហកម្មដ៏ខ្លាំងក្លា និង យៀកណាមខាងត្បូងសម្បូរណ៍ធនធានកសិកម្ម អាចបំពេញគ្នាទៅវិញទៅមក ហើយក្លាយទៅជាសេដ្ឋកិច្ចមួយលូតលាស់លឿននៃអាស៊ីភាគអគ្នេយ៍ ។ ភាពសម្បូណ៌ទៅដោយវត្ថុធាតុដើមជាតិរ៉ែ និងថាមពល ភាពចំរើនលូតលាស់នៃវិទ្យាសាស្ត្រ ផ្សារដ៏ធំធេងគុណសម្បត្តិរបស់កសិកម្ម ។ល។ ដែលគេសង្កេតឃើញមាននៅប្រទេសយៀកណាមសព្វថ្ងៃនេះ សុទ្ធសឹងជាកត្តានៃការរីកចំរើនលូតលាស់នៃឧស្សាហកម្មជាតិ នៃប្រទេសនេះ ។ ថ្វីបើប៉ុន្មានឆ្នាំនេះ ប្រទេសយៀកណាមត្រូវខូចខាតខ្ទេចខ្ទីសឹងតែទាំងអស់ នូវសន្ធារណៈគ្រប់បែបយ៉ាងក្តី សហរដ្ឋអាមេរិកមិនអាចចាកចេញពីយៀកណាមក្រោយដែលសង្គ្រាមចប់ ហើយដោយទុកឲ្យប្រទេសនេះស្ថិតក្នុងស្ថានភាពដុនដាបដូច្នេះឡើយ ។ ស.រ.អា. ប្រាកដជាស្តាបនាយៀកណាមឡើងវិញ ដើម្បីលុបលាងខ្លួនចំពោះប្រវត្តិសាស្ត្រមនុស្សជាតិ ។ ដូច្នេះហើយ សេដ្ឋកិច្ចយៀកណាមមុខជាលេបសេដ្ឋកិច្ចនៃប្រទេសដទៃៗ ជិតខាងមិនលែងឡើយ ។ នេះជាជំហានទៅកាន់ការបាត់បង់នូវឯករាជភាពនៃយើង ។*

*គឺពេលនេះហើយ ដែលប្រវត្តិសាស្ត្រនឹងបែងនូវ* “ដំណើរឆ្ពោះមកកាន់ទិសខាងលិច” *នៃប្រជារាស្ត្រយៀកណាមជាពិតប្រាកដ ។*

x

x x

# នយោបាយ «មហាប្រទេសយៀកណាម» ?

**La politique du Grand Vietnam?**

យើងពុំហ៊ានសន្និដ្ឋានអ្វីទុកជាមុន ឲ្យប្រាកដប្រជា នឹងអាចយកជាក្បួនតម្រាត្រឹមត្រូវ ចំពោះអនាគតនៃវាសនាជាតិយើង នោះវាពិតមែនហើយ តែយើងត្រូវតែមានកាតព្វកិច្ចពេញលេញក្នុងបញ្ហានេះ ដើម្បីទាញនូវមេរៀនខ្លះៗ ដែលប្រវត្តិសាស្ត្របានធ្លាប់ស្គាល់ មានការពិសោធន៍រួចមកហើយ ។ ឧទាហរណ៍ ដែលមានលក្ខណៈជាសារវន្តនោះ មិនខ្វះទេក្នុងប្រវត្តិសាស្ត្រ នៃពិភពលោកយើងនាសម័យអតីតកាលថ្មីៗនេះ ។ យើងនៅចាំយ៉ាងជាក់ស្តែង ក្នុងស្មារតីយើងម្នាក់ៗ នៅឡើយថា ក្នុងសម័យមុនសង្គ្រាមលោកលើកទី២ ប្រទេសអាល្លឺម៉ាញ (Allemagne) បានផ្តល់ចំពោះមនុស្សជាតិនូវមេរៀនមួយជាដំណាំ។

ការអ្វីដែលគេស្មានថាពុំអាចកើតមានឡើងសោះ ជួនកាលក៏អាចកើតមានឡើងបានដែរ ហើយការនេះវាស្រេចទៅលើទេសៈកាលៈនាកាលសម័យផង ស្រេចទៅលើឆន្ទៈនៃអ្នកនយោបាយជាតិនោះផង ។ ប្រទេសអាល្លឺម៉ាញ បានអនុវត្តនូវទ្រឹស្តីនយោបាយរបស់អ្នកដឹកនាំឈ្មោះហ៊ីត្លែរ (Hitler) ទាមទារឲ្យប្រជាជាតិអាល្លឺម៉ង់ មានសិទ្ធិរស់នៅលើដែនដីមួយធំ ហើយដែលគេចាត់ដែនដីនេះ ជាអាយុជីវិតរបស់គេ (Théorie de l'Espace Vital) ។

ចលនានៃការទាមទារពង្រីកទឹកដីនេះ ជនជាតិអាល្លឺម៉ង់គេបានធ្វើឡើង ដោយអាងទៅលើគំនិតខុសមួយដែលថែងថា ប្រជាជាតិអាល្លឺម៉ង់ ជាប្រជាជាតិខ្លាំងពូកែខ្ពង់ខ្ពស់ជាងគេឯង ទៅលើជនជាតិដទៃទៀត មានជនជាតិស្លាវ (Slaves) និងឡាតាំង (Latins) ទាំងឡាយដែលរស់នៅក្នុងទ្វីបអឺរ៉ុបប៉ែកខាងកើត និងអឺរ៉ុបប៉ែកខាងលិចជាដើមនេះ ។ បើប្រសិនជាជនជាតិអាល្លឺម៉ង់ ជាជាតិខ្លាំងពូកែយ៉ាងនេះហើយ ធម្មជាតិត្រូវតែប្រគល់ទៅឲ្យប្រជាជាតិអាល្លឺម៉ង់នូវដែនដីមួយជំល្មម អាចឲ្យប្រជាជាតិរស់ដោយស្រួល (Lebensraum)! ។ កត្តាជាសារវន្តមួយទៀត គឺការចំរើនលូតលាស់ដ៏អស្ចារ្យ និងមហិទ្ធិឫទ្ធ នៃឧស្សាហកម្មនិងសេដ្ឋកិច្ចទូទៅ នៃប្រទេសអាល្លឺម៉ង់នេះឯង ហើយជាមួយនឹងកម្លាំងសេដ្ឋកិច្ចនេះ កម្លាំងយោធាគួរឲ្យព្រឺខ្លាចនៃប្រទេសនេះទៀតផង ដែលជំរុញឲ្យអ្នកដឹកនាំនយោបាយអាល្លឺម៉ង់សម័យណាស៊ីស្ត អនុវត្តដោយគ្មាន

ខ្វាចរអែង នូវទ្រឹស្តី ពង្រីកទឹកដីនិយម ដ៏ចង្រៃអពមង្គលនេះ ។ ដើម្បីសម្រេចនូវគោលបំណងអក់ព្វនេះ អ្នកនយោបាយអាល្លឺម៉ង់ ចាប់ផ្ដើមប្រកាសទាមទារតម្រូវឲ្យវិលចូលមកក្នុងមហាគ្រួសារអាល្លឺម៉ង់ នូវដែនដីបរទេស នាអឺរ៉ុបប៉ែកកណ្ដាលនិងខាងកើតទាំងឡាយណា ដែលមានជនជាតិភាគតិចអាល្លឺម៉ង់រស់នៅ ហើយដែលនិយាយភាសាអាល្លឺម៉ង់ផង ។ គឺក្នុងគំនិតដ៏ខ្មៅងងឹតនេះឯង ដែលអ្នកនយោបាយអាល្លឺម៉ង់បំបះបំបោរបង្កបង្កើតជាចលាចល ឬគណបក្សអាល្លឺម៉ង់ណាស៊ី ក្នុងចំណោមពពួកអាល្លឺម៉ង់ទាំងឡាយ ដែលនៅឯបរទេស គឺក្នុងប្រទេសជិតខាងនេះតែម្ដង ។ កាលបើមានជាអង្គការទាមទារស្វ័យត (Mouvements autonomistes) ឬចលនាទាមទារការផ្ដាច់ចេញ (Mouvements séparatistes) ដែលមានសញ្ជាតិអាល្លឺម៉ង់ ហើយចលនាទាំងនេះតែងបានអំពាវនាវឲ្យមាតុប្រទេសអាល្លឺម៉ាញ ជួយជ្រោមជ្រែងអង្គការខ្លួនដោយធ្វើអន្តរាគមន៍ផ្លូវសឹក នយោបាយឬទូតជាដើម ។

គឺទេសៈកាលៈនេះឯងហើយ ដែលហុចឱកាសល្អឲ្យអ្នកដឹកនាំអាល្លឺម៉ង់សំរេចនូវបំណងដ៏អាក្រក់នៃទ្រឹស្តីរបស់ខ្លួន ។ ក្នុងន័យនេះ ប្រទេសអូទ្រីសទាំងមូល (l'Autriche) ត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃនៃពួកណាស៊ីស្តនិយមក្នុងឆ្នាំ ១៩៣៦ ។ ដែនដីប៉ែកខាងលិចនៃប្រទេសឆេកូស្លូវ៉ាគី គឺតំបន់ស៊ុយដែត (La région des Sudètes) ដែលមានជនជាតិអាល្លឺម៉ង់រស់នៅ ពីចំនួនជាង ៣ លាននាក់ ត្រូវក្លាយទៅជាអាណាខែត្រអាល្លឺម៉ង់ ។ ក្រោយមក គឺប្រទេសឆេកូស្លូវ៉ាគីទាំងមូលទៀត ក៏ត្រូវក្លាយទៅជាដែនដីអាណាព្យាបាលអាល្លឺម៉ង់ទៀត ។ល។

ឧទាហរណ៍នេះ មានលក្ខណៈជាក់ស្ដែងណាស់ហើយ។ តើយើងអាចសួរថាតើព្រឹត្តិការណ៍ដ៏ខ្មៅងងឹតនេះ បែបអាចកើតឡើងសាថ្មីទៀត ឬ ក្នុងប្រវត្តិសាស្រ្តនៃមនុស្សជាតិ ។ ជាការពិតណាស់ ជួនកាលប្រវត្តិសាស្រ្តវិលចុះវិលឡើង ត្រឡប់មកក្រោយវិញក៏មាន. . . . ។ ការដែលយើងគ្រាន់តែក្រឡេកមើលទៅជនជាតិអាស៊ី ប៉ែកកណ្ដាល (Les Peuples de l'Asie Centrale) ដែលសព្វថ្ងៃនេះ ស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងនៃក្រុងម៉ូស្គូ (Moscou) ប៉ុណ្ណោះយើងក៏អាចមានគំនិតខ្លះដែរហើយ អំពីហេតុនៃកម្លាំងសេដ្ឋកិច្ចនយោបាយនិងយោធា នៃមហាប្រទេសមួយទៅលើប្រជាជាតិតូចតាច ។

ចុះនៅឧបទ្វីបឥណ្ឌូចិនវិញ តើឧទាហរណ៍ "អាល្លឺម៉ង់"អាចមានឡើងសាជាថ្មីទេ នៅក្នុងតំបន់យើងនេះ ? ការនេះស្រេចទៅលើប្រវត្តិសាស្រ្តប្រាប់យើងក្នុងអនាគតចុះ. . . យើង

គ្រាន់តែសូមផ្តល់នូវ វិភាគ នៃស្ថានការណ៍នយោបាយនិងសេដ្ឋកិច្ចក្នុងជ្រោយឥណ្ឌូចិន តែប៉ុណោះ ដើម្បីជាការពិចារណាតទៅ ៖

ប្រជាជាតិ ឬ ប្រជារាស្ត្រយៀកណាម ជាប្រជាជាតិមួយដែលគេអាចចាត់ទុកដោយគ្មានលាក់លៀមថា មាន ថាមពល (dynamisme) មានគុណសម្បត្តិខាងផ្លូវបញ្ញា (les qualités Intellectuelles) គ្រប់គ្រាន់ ។ល។ សេដ្ឋកិច្ចប្រទេសវៀតណាមក្រោយសង្គ្រាម ជាសេដ្ឋកិច្ចដែលនឹងមានកម្លាំងក្លៀវក្លា ស្របជាមួយនឹងកំរិតខ្ពង់ខ្ពស់ខាងការអប់រំវិទ្យាសាស្ត្រ និងបច្ចេកទេសនៃជនជាតិនេះ ។ ម្យ៉ាងទៀត ខាងផ្លូវយោធា, ប្រទេសយៀក-ណាមនឹងមានកងទ័ពដ៏ខ្លាំងពូកែ ក្នុងចំណោមប្រជាជាតិទាំងឡាយ នៅជ្រោយឥណ្ឌូចិននិងក្នុងអាស៊ីភាគអគ្នេយ៍នេះ ។ ក៏ប៉ុន្តែហេតុការណ៍មួយទៀត ដែលយើងមានការបារម្ភពន់ពេកនោះ គឺជាការដែលមានអាណានិគមជនជាតិយួន (les colonies vietnamiennes) យ៉ាងសំខាន់ ក្នុងប្រទេសជិតខាងទាំងឡាយ :

នៅប្រទេសកម្ពុជា - ជាង ៥០០ ០០០ នាក់ (១)

ប្រទេសលាវ-ជាង៥០ ០០០នាក់ (បើបូករួមនឹងទាហានយៀកណាមខាងជើង)

ប្រទេសសៀម - ជាង ៥០ ០០០ នាក់ ។

នៅប្រទេសកម្ពុជាយើង គ្រាន់តែចំនួននៃជនបរទេសយួននេះ ធ្វើឲ្យយើងមានការបារម្ភនោះពន់ពេកណាស់ទៅហើយ ។ ហើយប្រសិនបើការលួចចូលមកកាន់តែច្រើនបន្តទៅទៀត គេពិបាកនឹងសន្និដ្ឋានណាស់ចំពោះផលវិបាក ខាងផ្លូវសេដ្ឋកិច្ចក៏ដូចជាខាងផ្លូវនយោបាយដែលប្រទេសយើងត្រូវទទួលរងគ្រោះ ។ ជាពិសេសណាស់ទៅទៀត ជនជាតិយួនទាំងនេះពុំងាយនឹងរលាយចូលទៅក្នុងសង្គមជាតិនានាទាំងនោះឡើយ គេនៅថែរក្សាប្រពៃណី ទំនៀមទម្លាប់យួន នឹងបំណងខាងផ្លូវចិត្តឬនយោបាយជាមួយនឹងមាតុប្រទេសដើមកំណើត ។ គឺក្នុងគំនិតនេះហើយ ដែលគេត្រូវចាត់ទុកជនជាតិយួនថាជា គ្រោះថ្នាក់យ៉ាងធំ មួយខាងផ្នែកនយោបាយ ។

ការដែលប្រទេសវៀតណាម នឹងត្រូវលូតលាស់ដុះដាលក្រោយសម័យសង្គ្រាមនេះទៅ នឹងអាចធ្វើឲ្យបំណងផ្លូវចិត្តនិងផ្លូវនយោបាយនៃជនជាតិយួនទាំងនេះរឹតតែមានលក្ខណៈមាំទាំខ្លាំងឡើងជាពុំខាន ។ ឯចំពោះបញ្ហាជនជាតិចិនក្នុងប្រទេស

---

(១) ក្រោយថ្ងៃ១៨ មីនា១៩៧០, ជនជាតិយួនជាង ១០០ ០០០ នាក់ ត្រឡប់ទៅ យៀកណាមខាងត្បូងវិញ ។

*យើង មានលក្ខណៈផ្សេង ដោយសារស្ថានភាពភូមិសាស្ត្រនយោបាយនៃប្រទេសយើង* (La situation géo-politique) *និងដោយសារជនជាតិចិនទាំងនោះ យូរឬឆាប់អាចជ្រួតជ្រាបរលាយចូលនឹងសង្គមជាតិយើងបន្តិចម្តងៗ ។ ហេតុដូច្នេះហើយ បានជាយើងអាចអះអាងដោយគ្មានរអែងថា មហាគ្រោះថ្នាក់ដល់អាយុជីវិតប្រជាជាតិខ្មែរយើងក្នុងអនាគតខាងមុខ* **ពីការលូតលាស់ដុះដាលជាសាថ្មីឡើងវិញ** *នៃប្រជាជាតិយៀកណាមនេះឯង* ( la renaissance nationale vietnamienne ) *ហើយជាបឋម, ក្នុងបច្ចុប្បន្នកាល ក៏ដូចក្នុងអនាគតកាលជិតៗនេះ, សន្ទុះនៃសេដ្ឋកិច្ច និងការឃោសនាផ្សព្វផ្សាយនៃមនោគមវិជ្ជាបដិវត្តនេះតែម្តង ។*

x

x x

# តើយើងត្រូវធ្វើដូចម្ដេច ?

ការដែលយើងលើកយកគ្រោះថ្នាក់ដ៏ធំធេងនេះ មកពិចារណាពន្យល់បំភ្លឺដល់សម្បជញ្ញៈនៃយើងរាល់គ្នាយ៉ាងដូច្នេះ មិនមែនបានសេចក្ដីថា យើងចាត់ប្រជាជាតិយៀកណាម **ជាសត្រូវពីដូនតាអស់មួយជីវិតជាតិយើងឡើយ** (Ennemi hériditaire) ។ ឯយើងវិញ ក៏ដូច្នោះដែរ **យើងមិនឲ្យប្រជារាស្ត្រយួនដដែលនេះ** ចាត់យើងទុកជាសត្រូវអស់មួយជីវិតដូចគ្នាដែរ ។ អតីតកាលគឺអតីតកាល **យើងមិនត្រូវច្រឡំអតីតកាល ជាមួយនឹងបច្ចុប្បន្នកាលឬអនាគតកាលសោះឡើយ** ។ ឧត្តមគតិយើង ក៏ដូចជាឧត្តមគតិជនជាតិ មានអារ្យធម៌នានាក្នុងលោកដែរ យើងដៅទៅរកការកសាង **អនាគតមួយដែលភ្លឺស្វាង** ដែលល្អប្រពៃ ដោយពឹងផ្អែកទៅលើការយោគយល់គ្នាទៅវិញទៅមករវាងជាតិនិងជាតិ ។ ការទាំងនេះនឹងត្រូវសម្រេចឡើងដោយយោងទៅតាមមេរៀនប្រវត្តិសាស្ត្រ ដែល**យើងមិនចង់ឲ្យប្រវត្តិសាស្ត្រនេះ វិលថយក្រោយសោះឡើយ** ។ យើងហាក់ដូចជាបានទទួលការកក់ក្ដៅច្រើនណាស់ អំពីសំណាក់អ្នកនយោបាយប្រទេសយួន**សម័យនេះ** ដោយគេបានសន្យាថានឹងមិនធ្វើ “អុកឡុក” ដល់ប្រទេសយើងឡើយ[(១)] គេនឹងគោរពទទួលស្គាល់អធិបតេយ្យភាពនិងបូរណភាពទឹកដីយើង ។ យើងក៏យល់ដែរនូវសន្ដានចិត្តនៃអ្នកជិតខាងយើងនេះ ។ តែគួរគប្បីយើងយល់ថានេះជា **បច្ចុប្បន្នកាល** ចុះដល់ **អនាគតកាល** យូរទៅ ? តើយុវជនឬប្រជារាស្ត្រយួននេះ នៅតែរក្សានូវសេចក្ដីគោរពនិងការទទួលស្គាល់នេះតទៅទៀត ? សម័យមួយខុសសម័យមួយទៀត ហើយការដោះស្រាយបញ្ហាក៏សំរេចទៅលើ **ការវិវត្តន៍** នេះដែរ ។ ក៏ប៉ុន្តែជាការពិតណាស់ **ទុកណាជាអ្នកដឹកនាំយួនទាំងឡាយនេះមានសន្ដានចិត្តល្អដូចម្ដេចម្ដាក្ដី ចំពោះយើង ក៏អ្នកទាំងនេះពុំអាចរារាំងឃាត់ឃាំង មិនឲ្យគ្រោះថ្នាក់នេះមានចំពោះមាតុប្រទេសយើងបានឡើយ ព្រោះនេះជាច្បាប់ធម្មជាតិ ជាលទ្ធផលនៃការវិវត្តន៍អារ្យធម៌ពីរ ដែលមានតម្លៃមិនដូចគ្នា** (Ce serait l'aboutissement logique d'un long processus d'évolution de deux civilisations voisines de valeur inégale).

---

(១)- អត្ថបទនេះសរសេរមុនថ្ងៃ១៨មីនា១៩៧០

ហេតុដូច្នេះ ប្រសិនបើគ្រោះថ្នាក់នេះមានភាពជាក់ស្តែង ហើយដែលអាចក្លាយទៅជាការគំរាមកំហែងដ៏កាចសាហាវចំពោះវាសនាជាតិយើង យើងត្រូវតែយកបញ្ហានេះ មកចងចាំផ្តិតជាប់ក្នុងស្មារតីនិងក្នុងសម្បជញ្ញៈនៃប្រជាជាតិយើង ។ អាវុធដែលវិសេសវិសាលឯណា ពុំអាចធ្វើឲ្យគោលបំណងមនុស្សសម្រេចជោគជ័យបានឡើយ បើមនុស្សដែលកាន់អាវុធនេះខ្វះ សម្បជញ្ញៈ គ្រប់គ្រាន់ ចំពោះគ្រោះថ្នាក់ដែលអាចប្រល័យជីវិតខ្លួននិងចំពោះ កាតព្វកិច្ច ជាសារវន្តរបស់ខ្លួនឯងយ៉ាងនេះ ។ ដូច្នេះហើយ ចំពោះប្រជាជាតិយើង អាវុធដែលសក្តិសិទ្ធ បំផុតអាចជួយយើងឲ្យផុតពីមហន្តរាយបាន គឺ " សម្បជញ្ញៈជាតិ " នេះឯងហើយ (la conscience nationale) ។ មានសម្បជញ្ញៈជាតិ គឺ ស្គាល់តម្លៃដ៏វិសេសវិសាលនៃជាតិខាងផ្លូវវប្បធម៌ក៏ដូចជាខាងផ្លូវសង្គម (la valeurs socio-culturelles) ។ ម្យ៉ាងទៀត មានសម្បជញ្ញៈជាតិ គឺមិនគ្រាន់តែពង្រីកនូវការស្នេហាជាតិ (le patriotisme) ប៉ុណ្ណោះទេ ថែមទាំងពង្រីកនូវលទ្ធិ **ជាតិនិយម** (le nationalisme) នេះទៀត ។

លទ្ធិជាតិនិយមខាងផ្លូវនយោបាយ និងផ្លូវសេដ្ឋកិច្ចជាអាវុធនៃការគង់វង្សជីវិតនៃប្រជាជាតិយើង (le nationalisme politique et économique constitue l'unique arme de notre survie en tant que nation dans cette partie du monde)

លទ្ធិ ជាតិនិយមជាទ្រឹស្តី នយោបាយ មិនមែនគ្រាន់តែបានសេចក្តីថា ការស្នេហាជាតិ ដែលគ្រាន់តែជាមនោសញ្ចេតនាមួយ ក្នុងចំណោមមនោសញ្ចេតនាទាំងឡាយ នៃមនុស្សម្នាក់ៗឡើយ ។ លទ្ធិជាតិនិយម ជាលទ្ធិដែលដៅទៅលើការ លើកតម្លៃខ្ពង់ខ្ពស់នៃលក្ខណជាតិ នៃមនោគមវិជ្ជាជាតិ និងអ្វីៗទាំងឡាយដែលទាក់ទងចំពោះប្រជាជាតិ ។ ទាំងអស់នេះ គឺធ្វើឲ្យសម្រេចនូវ ឧត្តមគតិដ៏ខ្ពង់ខ្ពស់របស់ជាតិដូចជាការ លូតលាស់ ការរីកដុះដាលនៃកម្លាំងរបស់ជាតិ ខាងផ្លូវនយោបាយដូចជាខាងផ្លូវសេដ្ឋកិច្ចឬយោធាដែរ ។

គឺក្នុងឧត្តមគតិនេះហើយ ដែលកាតព្វកិច្ចជាបឋមរបស់យើង គឺ ការពង្រឹងនៃលទ្ធិជាតិនិយមរបស់យើង (Renforcer notre nationalisme) ធ្វើឲ្យលទ្ធិនេះមានគ្រឹះមាំមួន (Fondements solides) អាចក្លាយទៅជាមនោគមវិជ្ជាជាតិប្រកបដោយប្រសិទ្ធភាពជាក់ស្តែង ។ គឺបើនិយាយឲ្យខ្លី គឺធ្វើឲ្យពាក្យ «ជាតិនិយម» មាន ន័យពេញលេញ ។ ម្យ៉ាងទៀត លទ្ធិនេះអាចលូតលាស់លឿនទៅមុខបាន ក៏អាស្រ័យទៅលើការលូតលាស់ លទ្ធិប្រជាធិបតេយ្យ (la démocratie) ដែលអនុញ្ញាតឲ្យប្រជារាស្ត្រអាចចូលរួបរួមពិតប្រាកដ ក្នុងកិច្ចការរដ្ឋ (la participation réelle et profonde du peuple dans les

affaires de l'Etat ) ហើយអាស្រ័យទៅលើការដុះដាលនៃយុត្តិធម៌ផ្លូវសង្គម ( la justice sociale ) ជាក់ស្តែង ។ បើកត្តាជាសារវន្តទាំងពីរគ្មានទេ ពាក្យជាតិនិយម ឬស្រឡាញ់ជាតិគ្រាន់តែជាស្ករកំបែកតែប៉ុណ្ណោះ ពុំអាចយកជាដុំកំភួនអ្វីបានឡើយ ។

**កត្តា "មនុស្ស"** ( le facteur humain ) **ជាកត្តាធំបំផុតក្នុងកិច្ចការកសាងជាតិនៅរកសេចក្តីចំរើនដល់កំរិតខ្ពង់ខ្ពស់នៃអារ្យធម៌ជាតិ** ។

កាលបើកត្តាមនុស្សមានសភាពថ្លៃថ្លាហើយ ការស្ថាបនាសេដ្ឋកិច្ចជាតិ ជាកាតព្វកិច្ច **ចុងក្រោយបង្អស់** ។ ធ្វើប្រទេសកម្ពុជាឲ្យក្លាយទៅជាប្រទេសលូតលាស់ មានកម្លាំងសេដ្ឋកិច្ចគ្រប់គ្រាន់ អាចឈមមុខទប់ទល់នឹងកម្លាំងផ្សព្វផ្សាយនៃសេដ្ឋកិច្ចប្រទេសជិតខាងយើង នេះហើយដែលជាសេចក្តីប្រាថ្នាចុងក្រោយនៃប្រជាជាតិយើង ។ គេនិយាយថា **សេដ្ឋកិច្ចដឹកនាំនយោបាយ** ( L'économie dirige la politique ) ។ ហើយគេនិយាយទៀតថា បើសេដ្ឋកិច្ចយើងខ្សោយ យើងពុំអាចនឹងសម្រេចបានទូវ **ឯករាជ្យនយោបាយ** បានឡើយ ( L'indépendance politique ) ។ បានសេចក្តីថា បើសេដ្ឋកិច្ចយើងខ្សោយ " ពាក្យឯករាជ្យនយោបាយ " នេះ គឺគ្រាន់តែពាក្យទទេ គ្មានសារៈសំខាន់អ្វីសោះ ។ យើងកុំនិយាយឡើយដល់ទៅចង់សម្រេចឲ្យមាន " **ឯករាជ្យសេដ្ឋកិច្ច** ( L'indépendance économique ) ពេញលេញ ពីព្រោះនេះគ្រាន់តែពាក្យស្មោកតែប៉ុណ្ណោះ ។ **សម័យនេះមិនមែនសម័យ ដែលរស់នៅពឹងផ្អែកទៅលើខ្លួនឯងទាំងស្រុង** (L'autarcie) បំបាត់ការទាក់ទងខាងផ្លូវសេដ្ឋកិច្ចជាមួយបរទេស . . . ។ មានតែមហាអំណាចមួយ ឬ ពីរប៉ុណ្ណោះក្នុងលោកនេះទេ ដែលអាចសម្រេចនូវឯករាជ្យសេដ្ឋកិច្ចនេះបាន ដោយអាងទៅលើភោគទ្រព្យដ៏ឥតគណនា ដែលធម្មជាតិលោកបានប្រទានមកឲ្យប្រទេសទាំងនេះ ។ ចុះចំពោះប្រទេសយើង ដែលគ្មានធនធានពីធម្មជាតិអ្វីប៉ុន្មានក្រៅអំពី **ដីល្បប់ទន្លេមេគង្គ** ប្រកបទៅដោយ **ជីជាតិ** និង **ទឹកដ៏បរិបូណ៌** ឥតគណនា និង **កំដៅព្រះអាទិត្យ** គឺយើងមានតែ **ធនធានទាំង ៣ ប៉ុណ្ណោះសោះ** (ដី ទឹក កំដៅ) ។ ហេតុយ៉ាងនេះហើយបានជា មូលដ្ឋាននៃសេដ្ឋកិច្ចជាតិយើង គឺ **កសិកម្មនេះឯង** ។

យើងមានធនធាន ៣ ហើយ ខ្វះតែមួយទៀតប៉ុណ្ណោះ ដើម្បីសម្រេចនូវការលូតលាស់បាន គឺការអប់រំកសិករយើងទៅតាមបច្ចេកទេស និងវិទ្យាសាស្ត្រទំនើប (l'information technique des agriculteurs) ប្រសិនបើកសិកម្មយើងលូតលាស់ពេញទំហឹងហើយ ប្រទេសនឹងអាចក្លាយទៅជា «កំពូល» ក្នុងភូមិភាគអាស៊ីអគ្នេយ៍យើងនេះ ( le Cambodge serait "roi" de l' Asie du Sud-Est ) ។ តើបាតុភូតទាំងនេះឬ ដែលជា

មូលដ្ឋានដ៏វិសេសវិសាល ទ្រទ្រង់នូវលទ្ធិជាតិនិយមសេដ្ឋកិច្ចរបស់រដ្ឋខ្មែរយើង ? យើងមានគ្រប់គ្រាន់ហើយមូលដ្ឋានទាំងនេះ យើងនៅខ្វះតែធនុៈ ប្រៀបបាននឹងដែក ឬការប្តេជ្ញាចិត្តទាំងស្រុងតែប៉ុណ្ណោះទៀតទេ ដែលសេដ្ឋកិច្ចកសិកម្មយើងនឹងត្រូវចាប់ផ្តើមដើរទៅមុខ ។ ១០ ឬ ២០ ឆ្នាំទៀត នយោបាយនេះប្រាកដជាឲ្យផលជាក់ស្តែងជាពិតប្រាកដ ។

ម្យ៉ាងទៀត ៣០ឆ្នាំទៀត បណ្តាជនយើងកើនដល់ទៅ ១៥លាននាក់ ប្រទេសយើងនឹងក្លាយទៅជាប្រទេសធំសម្បូរសប្បាយមួយ ជាមហាប្រទេសមួយក្នុងភូមិភាគអាស៊ីប៉ែកខាងត្បូងមិនលែងឡើយ ។

ពេលនោះហើយ ដែលប្រជាជាតិយើងឈប់មានព្រៀប **អោនថយជាងគេ** (Complexe d'infériorité) មានមុខមាត់ជាប្រទេសមួយ ដែលមានជ័យជំនះទៅលើភាពខ្សត់ខ្សោយ បានរើបម្រះចេញពីនឹមនៃប្រវិត្តសាស្រ្ត ក្រោយសម័យមហានគរ ( Ce sera la libération définitive de notre peuple de tant de siècles de décadence et d'écrasement physique et moral ) ។

ធ្វើយ៉ាងនេះ គឺប្រាកដជាយើងប្រគល់ទៅឲ្យប្រជាជាតិយើងវិញនូវសេចក្តីក្លាហាន ថាមពល និងសេចក្តីថ្លៃថ្នូរដែលបាត់បង់អស់រយៈពេលជាង ៦ សតវត្សរួចមកហើយ ។

x

x x

# សេចក្តីបញ្ចប់

នៅក្នុងពិភពមួយដែលកម្លាំងសេដ្ឋកិច្ច ប្រែក្លាយទៅជាកម្លាំងលើសលប់ក្នុងការទ្រទ្រង់នូវការគង់វង្សជីវិត ( la survie ) ជាតិ, ហើយម្យ៉ាងទៀត នៅក្នុងភូមិភាគនេះ ដែលសភាពរំពើតរំពើនខ្វះស្ថេរភាពជាអចិន្ត្រៃយ៍ ធ្វើឲ្យយើងពិបាកប្រមើលនូវអនាគតកាល ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពភូមិសាស្ត្រនិងនយោបាយមួយ ដែលមានលក្ខណៈស្មុគស្មាញ រកអ្វីប្រដូចមិនបានឡើយ ។ ស្ថានភាពនេះ ពិតជាគ្រោះថ្នាក់មួយដែលគំរាមកំហែងប្រទេសយើងរាល់ជំហាន នៃការវិវត្តន៍នៃប្រទេស ។ ដើម្បីនឹងការពារមាតុប្រទេសប្រឆាំងនឹងគ្រោះថ្នាក់នេះ យើងត្រូវតែប្រមូលនូវកម្លាំងចិត្តកម្លាំងកាយ ដើម្បីស្ថាបនាប្រទេសកម្ពុជាឲ្យក្លាយទៅជា ប្រទេសមួយលូតលាស់ មានកម្លាំងសេដ្ឋកិច្ចគ្រប់គ្រាន់ អាចទប់ទល់នឹងការផ្សព្វផ្សាយនៃកម្លាំងសេដ្ឋកិច្ចរបស់ប្រទេសជិតខាង ដែលសុទ្ធសឹងតែជាប្រទេសធំៗ មានកម្លាំងសេដ្ឋកិច្ចនិងនយោបាយគួរឲ្យយើងមានការព្រួយបារម្ភ ។

ការគង់វង្សជីវិតនៃប្រជាជាតិយើង ក្នុងស្ថានការណ៍ដ៏លំបាកនេះ វាស្រេចទាំងស្រុងទៅលើមូលដ្ឋានដែលមានលក្ខណៈប្រាកដនិយម ហើយមាំទាំរឹងប៉ឹងទៀតផង ។ ឯមូលដ្ឋាននោះ យើងរំពឹកម្តងហើយម្តងទៀតចុះ គឺគ្មានអ្វីក្រៅពីធនធានកសិកម្ម ឡើយ។ កសិកម្មយើងលូតលាស់ បានសេចក្តីថាសេដ្ឋកិច្ចជាតិយើងលូតលាស់ បានសេចក្តីទៀតថា យើងមានអាវុធគ្រប់គ្រាន់ ដើម្បីប្រយុទ្ធប្រឆាំង នឹង ការសង្កត់សង្កិន ខាងផ្លូវសេដ្ឋកិច្ចអំពីសំណាក់ នៃចក្រពត្តិនិយម និង អាណានិគមសម័យថ្មី និងអំពីសំណាក់នៃអ្នកជិតខាងយើង ។

យើងសូមដកស្រង់ពាក្យបណ្ឌិតនេរុ ( Nehru ) ដើម្បីបញ្ចប់អត្ថបទនេះ ៖

*« ដរាបណាសេដ្ឋកិច្ចយើងនៅទន់ខ្សោយ ដរាបនោះ យើងរស់នៅ ហាក់បីដូចជាគ្មាននយោបាយក្រៅប្រទេសឡើយ ព្រោះយើងមិនទាន់តាំងខ្លួនជាចៅហ្វាយលើខ្លួនយើងបាននៅឡើយ ។ ឯ "ឯករាជ្យនយោបាយ" នោះសោតទៀត គ្រាន់តែជាឧត្តមគតិនៅឡើយសម្រាប់លួងចិត្តយើង កុំឲ្យយើងខកចិត្តតែប៉ុណ្ណោះ » ។*

**នួន យឿន**

ភ្នំពេញ ថ្ងៃទី ២៤ កញ្ញា ១៩៦៩

# ដំណើររន្ធត់

# ទៅទិសខាងលិច [១]

ក្នុងលេខក្រោយបង្អស់នៃទស្សនាវដ្ដី (Etude Cambodgienne) ដែលបានបោះពុម្ពឡើងដោយក្រសួងឃោសនាការជាតិ, លោក ស្ហាល មែយៀរ ( Charles Meyer ) ក្នុងទំព័រវិចារណកថាបានសរសេរក្នុងក្របខ័ណ្ឌ នៃការទាក់ទង ខ្មែរ យៀកណាម ជាអាទិ៍ដូចតទៅនេះ : « វត្តមាននៃជនជាតិយួន ទៅលើទឹកដីខ្មែរជាគ្រោះថ្នាក់ខាងផ្លូវនយោបាយ ហើយផលវិបាកនៃហេតុការណ៍នេះបានលេចធ្លោ ឲ្យឃើញរួចមកហើយនៅតាមតំបន់ខ្លះៗ ។ គេបានសង្កេតឃើញថាពពួកអ្នកធ្វើការឃោសនាយួនមានសកម្មភាពយ៉ាងសំខាន់ នៅតាមភូមិជនបទខ្មែរនានា ហើយថែមទាំងបាន ណែនាំនិងដឹកនាំដល់ពពួកបះបោរដែលប្រកាន់មនោគមវិជ្ជាបែបយួននេះទៀតផង. . . » ។ ឆ្ងាយមកទៀត អ្នកនិពន្ធដដែលនេះ បានសរសេរទៀតថា ៖ « លក្ខណៈដ៏ធ្ងន់ធ្ងរមួយទៀត នៃបញ្ហា ខ្មែរ-យួន គឺការមកតាំងនៅដោយស្ងៀមស្ងាត់ នៃជនជាតិយួននៅលើទឹកដីនៃកម្ពុជា ( L'implantation pacifique des émigrés Vietnamiens en territoire Khmer ) »

« គ្រួសាររាប់រយគ្រួ ដោយសារការទម្លាក់គ្រាប់បែកនៃយន្តហោះអាមេរិកាំងបង្ខំឲ្យគេចាកចោលលំនៅកំណើតរបស់ខ្លួន, បានមកស្នាក់អាស្រ័យនៅប្រទេសកម្ពុជា ។ មួយភាគធំនៃអ្នកទាំងឡាយនេះ បានខិតខំរំពឹងទីតាំង នៅក្រោយការបញ្ចប់សង្គ្រាមទៀត ហើយការដែលគួរប្រហាក់ប្រហែលមួយទៀត គឺថានឹងមានជនជាតិយួនខ្លះ ដែលធ្លាប់បានត្រូវរ៉ូវជាមួយនឹងអាមេរិកាំង និងអាជ្ញាធរនៃក្រុងព្រៃនគរ កាលសង្គ្រាមចប់ហើយ នឹងឆ្លងកាត់ព្រំដែនមកជ្រកនៅលើដែនដីខ្មែរទៀត. . . ហើយការទាំងនេះនឹងប្រាកដជាបង្កើតឲ្យមាននូវសេចក្ដីព្រួយបារម្ភមួយយ៉ាងធំធេង ក្នុងបណ្ដាប្រជារាស្ត្រខ្មែរនៅតាមព្រំប្រទល់ដែន » ។

សេចក្ដីតែប៉ុណ្ណេះ យើងអាចយល់បានស្រេចទៅហើយថា តើគ្រោះថ្នាក់ភ្លាមៗនិងទៅអនាគតរដ្ឋខ្មែរយើងគឺត្រង់ណា ? ដូចយើងធ្លាប់បានយកបញ្ហានៃដំណើរឆ្ពោះមកទិសខាងលិច នៃជនជាតិយួននេះមកចោទរួចមកហើយ ចលនាមកទិសខាងលិចនេះ មិនត្រឹមតែមានលក្ខណៈនយោបាយ និងមនោគមវិជ្ជាទេ គឺថែមទាំងជាលទ្ធផលយ៉ាងជាក់ស្ដែង នៃការវិវឌ្ឍនៃប្រវត្តិសាស្ត្រនៃផែនដីអតីតឥណ្ឌូចិនបារាំងសេស ។ មុន

(១) អត្ថបទនេះបានចុះផ្សាយក្នុងសារព័ត៌មាន «នគរធំ» ពីថ្ងៃ ២០ ទៅ ២៨ ធ្នូ ១៩៦៩ – គឺ ៥ ខែមុនសង្គ្រាមកើតឡើងក្នុងប្រទេសយើង ។ ន.យ.

ដំបូង ជនជាតិយួនទាំងនេះបានធ្វើដំណើរមកពីទិសខាងត្បូងជាហូរហែ តាមជួរភ្នំអណ្ណាម ( Les Cordilières annamitiques ) ហើយក្នុងដំណើរនេះ ដែលមានអាយុច្រើនសតវត្ស បានលេបបាត់ទៅហើយ នគរចម្ប៉ាព្រមទាំងដែនដីកម្ពុជាក្រោមទៀតផង នៅដើមសតវត្សទី១៩ (ក្នុងរវាងឆ្នាំ១៨៤០) ។ ហេតុយ៉ាងនេះហើយ បានជាជ្រោយទឹកខ្មៅ ( Camau ) ជាដីខាងត្បូងបំផុតនៃឥណ្ឌូចិន ត្រូវជនជាតិយួនមកវាតទីតាំងនៅ ។

ដូច្នេះបើថ្ងៃមុខ មានការវាតទីតាំងទៀត គឺដំណើរឆ្ពោះទៅទិសខាងលិច ហើយមកប៉ះនឹងប្រទេសកម្ពុជាយើងតែម្តង ។ ឥឡូវព្រឹត្តិការណ៍នេះ ដោយសារមានសង្គ្រាមនៅវៀតណាម តាំងពីឆ្នាំ១៩៤៥ រហូតមកដល់បច្ចុប្បន្នកាលនេះ ជាកត្តាយ៉ាងធំ, បានមានរួចមកហើយ ហើយប្រាកដជានឹងមានកាន់តែធំឡើងៗ ទៅថ្ងៃមុខទៀត បើវិធានការដែលនឹងចាត់ពុំមានប្រសិទ្ធភាពគ្រប់គ្រាន់ទេនោះ ។

លក្ខណៈធ្ងន់ធ្ងរមួយទៀតនៃបញ្ហាស្មុគស្មាញនេះ គឺការដែលបណ្តាជនយួននេះមានការបង្កើនចំនួនមួយយ៉ាងលឿនគួរឲ្យប្រទេសជិតខាង មានការព្រួយបារម្ភជាចាំបាច់ ។ បើប្រសិនជាយើងយកស្ថិតិ ដែលគេបានធ្វើឡើងដោយវិធីវិទ្យាសាស្ត្រមកពិនិត្យការណ៍នេះ រឹតតែគួរឲ្យយើងឃើញជាក់ស្តែងណាស់ទៅទៀត ៖ ភាគរយនៃកំណើនចំនួនប្រជាជនខ្មែរយើង មានត្រឹមតែ ២,៥ ទៅ ២,៦ ភាគរយតែប៉ុណ្ណោះ ( le taux d'accroissement démographique ), ឯចំណែកយួន បើតាមអ្នកជំនាញការ ភាគរយនេះឡើងដល់ទៅ ៣ ភាគរយលើសយើងទៅទៀត ។ ម្យ៉ាងទៀតដល់ក្រោយសង្គ្រាមចប់ ភាគរយនៃការបង្កើននេះប្រហាក់ប្រហែលជានឹងឡើងហួសពី ៣ ភាគរយនេះទៅទៀត ។ ហេតុការណ៍នេះ អាចមានផលវិបាកជាធ្ងន់ធ្ងរពន់ពេក មកលើប្រទេសយើងនិងប្រទេសជិតខាង : ម្យ៉ាងទៀតក្នុងប្រទេសយួន ការកើនដ៏លឿននៃបណ្តាជននេះអាចបោទឲ្យមានជាបញ្ហាដីធ្លី ( problèmes agraires ) ដែលត្រូវឲ្យមានទំហំគ្រប់គ្រាន់ដើម្បីអាចចិញ្ចឹមមនុស្សកាន់តែច្រើនឡើងៗ ។ គ្រាន់តែសព្វថ្ងៃនេះ ចំនួនប្រជាជនខាងជើងនិងខាងត្បូងបញ្ចូលគ្នា ជាង ៤០ **លាននាក់នៅហើយ** ហើយបញ្ហាដីធ្លីមានបោទខ្លះៗរួចមកហើយ, ចុះដល់ ២០ ឬ ៣០ ឆ្នាំទៀត ប្រជាជននេះត្រូវគុណនឹងពីរ ពី ៧០ ទៅ ៨០ លាននាក់ ! តើបញ្ហានេះនឹងមានទំហំធំដល់ណាទៅ ? លើកលែងតែអនាគតសេដ្ឋកិច្ចយួន ក្លាយទៅទៅជាសេដ្ឋកិច្ចឧស្សាហកម្មយ៉ាងលូតលាស់ខ្លាំងណាស់ ទើបអាចដោះស្រាយបញ្ហានេះបាន បើមិនយ៉ាងនេះទេ ជនជាតិយួនទាំងនេះនឹងត្រូវចាកចេញពីប្រទេសខ្លួនមកនៅលើដីទាំងឡាយដែលនៅទំនេរ ហើយដីដែលនៅទំនេរទាំងនោះ

គឺដែនដីខ្មែរយើងតែម្តង ។ ឯចំណែកដែនដីប្រទេសលាវជាដីភ្នំ ហើយបើតាមប្រវត្តិសាស្ត្រទៀត ជនជាតិយៀកណាមនេះ ជាមនុស្សដែលចូលចិត្តរស់នៅលើវាលទំនាប ( l'homme de la plaine ) គឺដែនដីសណ្តនៃទន្លេមេគង្គតែម្តង ( le Delta ou la vallée du Mékong ) ។ម្យ៉ាងវិញទៀត ចូរយើងកុំភ្លេចថា បើដល់ឆ្នាំ ២០០០ ប្រជាជនខ្មែរយើងកើនដល់ទៅ១៥ លាននាក់ នេះបើតាមការស្មានតាមកម្មវិធីវិទ្យាសាស្ត្រ, ឯប្រទេសយៀកណាម នឹងកើនដល់ពី៧០ទៅ៨០លាននាក់ទៅហើយ ។ ម្យ៉ាងទៀត បើការស្រាយបញ្ហាប្រជាជននេះពុំបានស្រួលទេ នោះយើងបារម្ភខ្លាចក្រែងតែនឹងមានការបង្កើតក្នុងចំណោមបញ្ហាវគ្គយួនដែលមានគំនិតជាតិនិយមហួសហេតុ ( l'ultra-nationalisme ) នូវទ្រឹស្តីពង្រីកទឹកដីនិយម ដើម្បីឲ្យប្រជារាស្ត្រគេអាចរស់នៅបាន ( une nouvelle théorie de l'Espace Vital ) ។ ហើយបើទ្រឹស្តីនេះកើតឡើងមែននោះ, ផលវិបាកនឹងមានលក្ខណៈធ្ងន់ធ្ងរក្រៃលែង មកលើអនាគតប្រទេសកម្ពុជាយើង ។

ម្យ៉ាងវិញទៀត ឯក្នុងប្រទេសយើង ជនជាតិយួនដែលរស់ក្នុងស្រុកខ្មែរ យើងក៏កើនឡើងមិនដាច់ដែរ ។

សព្វថ្ងៃនេះ អាណិកជនជាតិយួនទាំងនោះ មានចំនួនពី ៤៥០,០០០ ទៅ ៥០០,០០០ នាក់ទៅហើយ[(១)] គឺជិតទៅ ៧ ភាគរយនៃបណ្តាជនខ្មែរយើងទាំងមូល ។ ហើយភាគរយនៃការកើនចំនួនប្រជាជនយួននៅក្នុងស្រុកយើងទៀត ក៏លើសភាគរយនៃកំណើតប្រជាជនយើងដែរ ដូច្នេះហើយ ការកើននេះត្រូវតែលឿនទៅមុខជាដរាប ដោយបូកបញ្ចូលជាមួយផងនូវការលបលួចចូលមកនៅ លើដីខ្មែរយើង ដោយឥតច្បាប់ទម្លាប់នោះទៀត។ យើងបានសង្កេតឃើញជាទូទៅថា ជនជាតិយួនដែលនៅស្រុកខ្មែរយើង ភាគច្រើនជាអ្នកក្រីក្រ ហើយភាពក្រីក្រនេះ អាចបង្កើតឡើងនូវបញ្ហាខាងផ្លូវសង្គមយ៉ាងធ្ងន់ធ្ងរ មានចោរកម្ម ឃាតកម្ម ភាពឥតការធ្វើ ល្បែងស៊ីសង ការលក់សម្លស្សខ្លួនដើម្បីរស់ ។ល។ ហើយដោយហេតុថាខ្មែរនិងយួនរស់នៅជិតៗគ្នា ជួនកាលមានការទាក់ទងគ្នាទៅវិញទៅមកផងក៏មាន ផលវិបាកនេះ នឹងត្រូវធ្លាក់មកលើសង្គមខ្មែរយើងឥតបើប្រកែកបានឡើយ។ នេះជាបញ្ហាខាងសង្គមវិទ្យា ( un problème sociologique ) គប្បីតែយើងចាប់អារម្មណ៍ដើម្បីឲ្យសង្គមខ្មែររក្សានូវភាពស្អាតស្អំភាពបរិសុទ្ធ ។

ព្រឹត្តិការណ៍មួយទៀត ដែលយើងគួរចាប់អារម្មណ៍ជាពិសេស ការបង្កើនចំនួនកាន់តែច្រើន នៃអាណិកជនបរទេសយួនលើផែនដីយើង ហើយបើយើងបូកបញ្ចូល

---

(១) មុន ១៨មីនា ១៩៧០ ។

ទាំងអាណិកជនបរទេសចិនមកទៀតផង នឹងអាចមានផលវិបាកមួយទៀតធ្ងន់ធ្ងរក្រៃលែង ក្នុងអនាគតកាល។ គ្រាន់តែសព្វថ្ងៃនេះ ជនបរទេសទាំងឡាយនេះ មានចំនួនជិត ឬជាងមួយលាននាក់ទៅហើយ ក្នុងចំនួនបណ្តាជនយើងទាំងអស់ជាង៨លាននាក់ ។ បើយើងនិយាយឲ្យបានច្បាស់ទៅទៀត គឺក្នុងខ្មែរទាំងអស់ ៧ នាក់ មានបរទេសចិន-យួន ១ នាក់ ។ ហេតុការណ៍នេះ អាចនឹងបណ្តាលឲ្យមានឡើងជា បញ្ហាសាសន៍ ( un problème racial ) ហើយដែលនឹងមានលក្ខណៈជាបញ្ហាផ្លូវសង្គមទៀតផង ។ នៅប្រទេសម៉ាឡាយូថ្មី ៗ នេះ មានផ្ទុះរឿងសាសន៍នេះ បណ្តាលឲ្យមានការវឹកវរ ខូចខាតនូវស្ថេរភាពខាងផ្លូវនយោបាយ ហើយសព្វថ្ងៃនេះក្តី បញ្ហានេះក៏មិនទាន់ចប់សព្វគ្រប់ទៅហើយដែរ ។ អាណិកជនបរទេសជាតិយួន នៅស្រុកយើងសព្វថ្ងៃនេះ ពុំមែននៅស្ងៀមស្ងាត់ប៉ុន្មានឡើយ គេមានអង្គការសម្ងាត់គ្រប់បែបយ៉ាង ខាងផ្លូវសាសនា ក៏ដូចជាខាងផ្លូវនយោបាយ ។ រឿងអស់នេះនរណាក៏ដឹងគ្រប់ៗ គ្នាហើយដែរ ។

សព្វថ្ងៃនេះ គេឃើញពួកគេ នៅហាក់ដូចជាស្ងៀមស្ងាត់ ពីព្រោះពេលនេះ យួនកំពុងជាប់ធ្វើសង្គ្រាម នៅប្រទេសវៀតណាម ហើយជា ប្រយោជន៍របស់គេធំណាស់ ដែលតម្រូវឲ្យគេមានការទាក់ទងយ៉ាងប្រពៃ ជាមួយអាជ្ញាធរខ្មែរយើង ។ ចុះដល់គេចប់សង្គ្រាមទៅ ប្រទេសគេរួបរួមគ្នាវិញឬទេ ?

បើមិនរួបរួមខាងផ្លូវនយោបាយក៏ខាងផ្លូវសេដ្ឋកិច្ច វប្បធម៌ដែរ ហើយប្រទេសគេនឹងក្លាយទៅជាមហាអំណាចអាស៊ីមួយ ដែលពិភពលោកបានទាយរួចមកហើយនោះ ជនជាតិវៀតណាមនៅស្រុកខ្មែរ ច្បាស់ជានឹងមានសម្បជញ្ញៈ ចំពោះកម្លាំងរបស់ខ្លួនមិនលែងឡើយ ( La prise de conscience de leur force en tant que minorité ethniquement et politiquement dominante ) ហើយនិងមានការទាមទារអ្វីផ្សេងៗ ខាងផ្លូវសង្គម ឬផ្លូវនយោបាយមិនលែងឡើយ ។

នេះជាគ្រោះថ្នាក់មួយធំអនេក ពីព្រោះនឹងអាចបណ្តាលឲ្យការល្អក់ ក្នុងការទាក់ទងខ្មែរ-យួន ទៅអនាគតកាលមិនចេះចប់ មិនចេះហើយ។ បានជាយើងហ៊ានអះអាងយ៉ាងនេះ មិនមែនដោយយើងមានគំនិតស្អប់ជនជាតិយួនពីដូនតា ( une haine héréditaire ) នោះមកទេ គឺមកអំពីការដែលយើងធ្វើវិភាគក្នុងបញ្ហាខ្មែរ-យួននេះតែម្តង។ នេះជាការវិវត្តិមួយ ដែលមានលក្ខណៈជាការចាំបាច់ ព្រោះប្រវត្តិសាស្ត្រមនុស្សជាតិ បានប្រទះបញ្ហាបែបនេះច្រើនណាស់មកហើយ ក្នុងសតវត្សទី ២០ នេះតែម្តង ។

## ឯណាការដោះស្រាយ ?

ការដោះស្រាយដែលប្រពៃ មិនមែនការប្រើ «ធមិក្តៅ» នោះទេ ព្រោះថាបើប្រើធមិក្តៅ នឹងបណ្តាលឲ្យមានប្រតិកម្មលក្ខណៈជា «ធមិក្តៅ» តបមកវិញ មិនចប់មិនហើយ និងធ្វើឲ្យជ្រោះរវាង ខ្មែរនិងយួន កាន់តែមានទំហំធំឡើងៗ អស់មានស្ថេរភាពនយោបាយ ក្នុងឥណ្ឌូចិនជាប្រាកដ ។ យើងនិយាយ «ធមិក្តៅ» នេះ គឺចង់និយាយដល់ការបង្ខំឲ្យអាណិកជនយួនទាំងនេះ វិលត្រឡប់ទៅស្រុកកំណើតវិញ (le rapatriement forcé) . . វិធានការនេះ បណ្តាលឲ្យមានផលវិបាកអាក្រក់ទៅលើសេដ្ឋកិច្ចជាតិ ៖ យើងនឹងបាត់បង់នូវក្រុមខណ្ឌសេដ្ឋកិច្ច និងបច្ចេកទេសច្រើន, ថែមទាំងផ្សារក្នុងប្រទេសយើងយ៉ាងសំខាន់ទៀត ដែលជាការចាំបាច់ចំពោះអនាគត ការលូតលាស់ឧស្សាហកម្មនិងសេដ្ឋកិច្ចប្រទេសកម្ពុជាយើង ។ ហើយទោះបីការបង្ខំឲ្យវិលទៅស្រុកកំណើតវិញ អាចធ្វើទៅកើតវានឹងបណ្តាលឲ្យមានបញ្ហាដ៏ធំ ដែលនឹងហួសសមត្ថភាពរបស់យើងទៀតផង។ ដូច្នេះ វិធានការដែលយើងអាចអនុវត្តទៅបាន ដោយមិនបង្កើតជាបញ្ហាធ្ងន់ធ្ងរពេកទេ គឺការត្រួតត្រាឲ្យបានជិតដល់ ដល់សកម្មភាពគ្រប់បែបយ៉ាងខាងផ្លូវ សាសនា ក្តី ខាង ផ្លូវសង្គម ឬ នយោបាយ ក្តី ដែលអាណិកជនជាតិយួនទាំងអស់មានក្នុងប្រទេសយើង ដើម្បីអាចឲ្យយើងរំងាប់ទាន់ ( neutraliser ) នូវគ្រប់បំណងអាក្រក់ទាំងឡាយ ដែលនឹងអាចចាប់ផ្តួចផ្តើមឡើង ។

ហើយសំខាន់ជាងនេះទៅទៀត គឺការបិទទល់ដែនឲ្យបានរឹងប៉ឹង គួរឲ្យមានការទុកចិត្ត ឈប់ឲ្យមានការលួចនាំចូលបរទេសមកតាមវិធីពាណិជ្ជកម្ម ឬ ដោយការស៊ីគ្រលំខ្វះសម្បជញ្ញៈ ។ យើងគួរយល់ថា បើមានការលបលួចចូលមកម្តងមួយកាល (Temporaire) នោះមិនមែនជាគ្រោះថ្នាក់ខ្លាំងក្លាប៉ុន្មានទេ គ្រោះថ្នាក់ដែលធំ គឺការមកតាំងទីលំនៅជានិច្ចកាល ( Implantations permanentes ) ដោយមានការសង់ផ្ទះសម្បែងចាប់ប្រកបកសិកម្ម ឬមុខរបរអ្វីផ្សេងៗទៀត ព្រោះជនប្រភេទនេះ ដែលមាន «ឫស» ជាប់នឹងដីយើងហើយ នឹងមានកូនចៅ មិត្តភក្តិ មិនងាយត្រឡប់ទៅវិញឯងៗ ឡើយ។ ហើយបើយ៉ាងនេះទៅ ទល់ដែនយើងនឹងត្រូវបរទេសយួនមកតាំងនៅកកកុញ រួចហើយក៏បណ្តាលឲ្យមានជម្លោះ រករឿងហេតុជាមួយនិងបងប្អូនខ្មែរយើង បង្កើតឲ្យមានការពិបាករស់នៅ ឯខ្មែរយើងជាជាតិស្លូតត្រង់ មិនជាអ្នករករឿងហេតុគេ ក៏ត្រូវ

*បោះបង់ចោលទីនោះ រត់មកនៅឆ្ងាយៗទៀត ។ល។ នេះប្រាកដជាការដណ្ដើមទឹកដីដោយវិធីស្ងៀមស្ងាត់ ដែលយើងគួរចាប់អារម្មណ៍ឲ្យបានជាក់ច្បាស់ ។*

*ដូចយើងបានធ្វើការរែកញែករួចមកហើយ សេចក្ដីសង្ឃឹមយើងទាំងស្រុងស្ថិតនៅលើរដ្ឋាភិបាលស្រោចស្រង់* ជាតិ ដែលនឹងមានសម្បជញ្ញៈច្បាស់លាស់ ចំពោះគ្រោះថ្នាក់ដ៏ធំធេងនេះ ដល់មាតុប្រទេសកម្ពុជារបស់យើង ។ បើបញ្ហាទាំងនេះមិនបានទទួលការដោះស្រាយ គួរជាទីកក់ក្ដៅទេ អនាគតរបស់យើងនឹងមានពពកខ្មៅងងឹតមកបាំងមិនខានឡើយ ក្នុងក្របខណ្ឌនៃការវិវត្តិនយោបាយទូទៅ ក្នុងភូមិភាគឥណ្ឌូចិនដ៏រំជើបរំជួលនេះ ។

***ស. ម៉ានិ***

ភ្នំពេញ ថ្ងៃទី២៣ ធ្នូ ១៩៦៩

# ឥណ្ឌូចិន

# ក្នុងឆ្នាំ២០០០...

*គំនិត ឬទ្រឹស្តីដែលថែងថា **បណ្តាជន*** ( la population ) *និងការវិវត្តន៍នៃបណ្តាជននេះមាន **នាទីដ៏សំខាន់** មួយនៅក្នុងជីវភាព **នយោបាយជាតិ** និងអន្តរជាតិនេះមិនមែនជាគំនិត ឬទ្រឹស្តីថ្មោងថ្មីទេ ។ ជាការពិតមែនហើយ ដែលគេពោលថា «មនុស្ស» ជាមូលដ្ឋានសារវន្តនៃគ្រប់របបគ្រប់គ្រងនយោបាយនៃប្រជាជាតិ ឬសង្គមមនុស្សទាំងឡាយ ។ ហេតុដូច្នេះបានជាចំនួនមនុស្សពោលគឺបណ្តាជនក្នុងប្រទេសនិមួយៗ ឬក្នុងតំបន់ភូមិភាគនិមួយៗ, ត្រូវតែមានឥទ្ធិពលជាការចាំបាច់ទៅលើស្ថានភាព ឬកិច្ចដឹកនាំនយោបាយ ក្នុងប្រទេសឬក្នុងភូមិភាគដែលប្រមូលផ្តុំប្រទេសទាំងនោះ ។ ដូច្នេះ បើយោលទៅតាមទ្រឹស្តីនេះ ចំនួនបណ្តាជននិងការដឹកនាំនយោបាយ ពុំអាចត្រូវគេអារកាត់ផ្តាច់ចេញពីគ្នាបានឡើយ ។*

# បណ្តាជនច្រើនហួសមាឌ

La surpopulation

*ដោយយោងទៅតាមទ្រឹស្តីខាងលើនេះ ប្រវត្តិវិទូនិងសង្គមវិទូ* ( Sociologue ) *ភាគច្រើនបានពន្យល់អំពីបុព្វហេតុនៃសង្គ្រាមរវាងជាតិនិងជាតិ* ( Causes des guerres ) *និង ចលនាបដិវត្តន៍* (mouvements révolutionnaires) *ដែលបានចាប់កំណើតឡើងក្នុងប្រទេសឬភូមិភាគនិមួយៗ នៃពិភពលោក ដោយពឹងផ្អែកទៅលើស្ថានភាពនិងចលនានៃការវិវត្តន៍នៃបណ្តាជននេះតែម្តង ។ ប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ហាក់ដូចជាបានកត់សំគាល់នូវព្រឹត្តិការណ៍ ជាគំរូខ្លះរួចមកហើយ ដែលអាចឲ្យយើងយកមកបញ្ជាក់បកស្រាយពន្យល់នូវទ្រឹស្តីខាងលើនេះ ៖ ក្នុងរវាងឆ្នាំ ១៩៣០, ប្រទេសអាល្លឺម៉ាញសម័យហ៊ីត្លែរ នៅទ្វីបអឺរ៉ុប, និងប្រទេសជប៉ុនសម័យយោធានិយមនៅទ្វីបអាស៊ី, បានធ្វើនយោបាយយោធានិយមដ៏ឃោរឃៅ បង្កបង្កើតឲ្យមានសង្គ្រាមក្នុងពិភពលោកព្រមទាំងបានផ្សព្វផ្សាយនូវសេចក្តីក្រៀមក្រំ និងការខ្ទេចខ្ទាំអស់រយៈជាច្រើនឆ្នាំ មកលើមនុស្សជាតិ ។*

*ប្រទេសទាំងពីរនេះ ក្នុងសម័យនោះ សុទ្ធសឹងជាប្រទេសដែលមានបណ្តាជនច្រើនហួសមាឌហួសសមត្ថភាពនៃការដោះស្រាយសាមញ្ញនៃប្រទេសទាំងពីរ ៖ ៦*

នយោបាយពង្រីកទឹកដីនិយម និងសង្គ្រាមឈ្លានពានទៅលើប្រជាជាតិជិតខាង ដែលប្រទេសទាំងនេះបានបង្កបង្កើតឡើង គឺពិតជានៅក្នុងគោលបំណងនយោបាយមួយយ៉ាងច្បាស់លាស់ គឺវាយដណ្ដើមយកទឹកដីបរទេសមកធ្វើជារបស់ខ្លួន ដើម្បីជាមធ្យោបាយអាចឲ្យប្រទេសខ្លួនមានដែនដីគ្រប់គ្រាន់ ( Espace vital ) សំរាប់ចិញ្ចឹមបណ្ដាជនរបស់ប្រទេសគេ ដែលកាន់តែកើនចំនួនច្រើនឡើងៗជាលំដាប់រៀងរាល់ឆ្នាំៗ គឺក្នុងគោលបំណងនេះហើយ ដែលដំបូងឡើងប្រទេស **ជប៉ុន** បានច្បាំងវាយដណ្ដើមយកដែនដី **កូរ៉េ** ( Corée ) និង **ម៉ាំងជូរី** ( Mandchourie ) នាប្រទេសចិនប៉ែកខាងជើង, ព្រមទាំងគំរាមកំហែងដល់អាណាខេត្តខ្លះនៃសហភាពសូវៀតផង ហើយបណ្ដាលឲ្យកើតមានសង្គ្រាមយ៉ាងយូរ ពីឆ្នាំ ១៩៣៦ ទៅទល់នឹងឆ្នាំ ១៩៤៥ រវាងចិននិងជប៉ុន ។

ឯប្រទេសអាល្លឺម៉ាញវិញ ក៏បានអនុវត្តនយោបាយឈ្លានពានទឹកដីតាំងពីឆ្នាំ ១៩៣៨ មកដល់ឆ្នាំ ១៩៤៥ ដោយបានវាយដណ្ដើមយកប្រទេស **អូទ្រិស, ប៉ូឡូញ** និង១ភាគធំនៃមហាប្រទេស **រុស្ស៊ី** ។ល។ ជាពិសេសទៅទៀត គេបានកត់សំគាល់ថាមានកំណើនចំនួនបណ្ដាជនទ្វេក្នុង ទ្វីបអឺរ៉ុបពីឆ្នាំ ១៨១៥ មកដល់ឆ្នាំ ១៩១៥ ហើយស្រាប់តែនៅដើមសតវត្សរ៍ទី២០នេះតែម្ដង ទ្វីបអឺរ៉ុបបានឆ្លងកាត់នូវសម័យមួយដ៏រំជើបរំជួល ហើយប្រទះនូវមហាសង្គ្រាមដល់ទៅពីរលើក គ្រាន់តែក្នុងរយៈពាក់កណ្ដាលនៃ សតវត្សរ៍ទី២០ តែប៉ុណ្ណោះ ។

ជាទីបំផុតគេសង្កេតឃើញម្យ៉ាងទៀតថា ក្នុងសម័យបច្ចុប្បន្ននេះ គ្រប់ប្រទេសខ្សត់ខ្សោយទាំងឡាយនៃតតិយលោក ( les pays sous développés ) ដែលទើបនឹងបានស្គាល់នូវកំណើនចំនួនបណ្ដាជន ដ៏លឿនហាក់បីដូចជាសន្ទុះព្រួញ កំពុងតែជួបប្រទះនូវ ចលនាបដិវត្តន៍ មួយដែលកំពុងតែរាលដាលផ្សព្វផ្សាយគ្រប់ទិសទី ដោយមានអង្គការ កុម្មុយនិស្តនិយមអន្តរជាតិ ជួយជ្រោមជ្រែងផង ។ ហើយចលនារំពើតរំពើនទាំងនេះ ត្រូវបានគេរៀបចំឡើងក្នុងគោលបំណងនឹងរំលំរបប នយោបាយសេដ្ឋកិច្ច សង្គមចាស់ទាមទារឲ្យមានរបបថ្មី ប្រកបដោយលក្ខណៈបដិវត្តន៍ ដែលគេយល់ថានឹងអាចដោះស្រាយបញ្ហាសង្គមមនុស្សបានដោយប្រសិទ្ធភាព ពិសេស បញ្ហាដែលទាក់ទងទៅនឹងកំណើនដ៏លឿនហួសប្រមាណ នៃបណ្ដាជននេះឯង ។ គឺក្នុងក្របខណ្ឌនៃទ្រឹស្ដីនេះឯងទៀត ដែលមានអ្នកប្រាជ្ញខ្លះមានលោក **គ្ញាសស្តុងប៊ូធុល** ( Gaston Bouthoul ) ជាសង្គមវិទូនិងប្រវត្តិវិទូជាតិបារាំង បានចាត់ទុក «សង្គ្រាម» ជាបាតុភូតមួយដ៏សំខាន់

មាននាទីជាអ្នកធ្វើឲ្យសំរេចឡើងនូវសមតា ( l'équilibre ) ក្នុងសង្គមមនុស្សទាំងឡាយនៃពិភពលោក ។

## នៅឥណ្ឌូចិន បណ្តាជនខ្មែរអាចទប់ នឹងបណ្តាជនយួននិងសៀមបានឬទេ ?

ដើម្បីយល់ឲ្យបានច្បាស់លាស់ នូវទំហំនៃគ្រោះថ្នាក់ជាអចិន្រ្តៃយ៍ ដែលគំរាមកំហែងប្រទេសកម្ពុជា ក្នុងអនាគតកាលខាងមុខនេះ គប្បីយើងរំឭកដល់ស្ថានការណ៍ប្រវត្តិសាស្រ្តជាក់ស្តែង (Situation de fait ) ខ្លះទុកជាគោលដៅជាបឋម ។ ក្នុងការវិវត្តន៍ជាហូរហែមកហើយ ក្នុងប្រវត្តិសាស្រ្តនៃប្រទេសទាំងបី ខ្មែរ សៀម យួន ទំនាស់ខ្មែរ សៀម, រួចទំនាស់ខ្មែរ-យួន ហើយចុងក្រោយបំផុត គឺទំនាស់សៀម-យួន ជាព្រឹត្តិការណ៍មួយមានលក្ខណៈជាអចិន្រ្តៃយ៍ ( Une permanence historique ) ក្នុងប្រវត្តិសាស្រ្តនៃប្រជាជាតិឥណ្ឌូចិន អស់កាលច្រើនសតវត្សរ៍រួចមកហើយ ។ ប្រទេសសៀមជាប្រជាជាតិមួយប្រកបដោយយុវភាព ( ប្រទេសសៀមចាប់កំណើតឡើងនាសតវត្សរ៍ទី ១៤ ) ក្រោយពីបានវាតទីតាំងលើដែនដីខ្មែរ មួយភាគយ៉ាងធំនៅប៉ែកខាងជើង និងខាងលិចប្រទេសកម្ពុជាបច្ចុប្បន្ន រួចហើយក៏បានខិតខំធ្វើនយោបាយប្រទាក់ប្រទាញប្រទេសខ្មែរ ឲ្យចូលទៅក្នុងការគ្រប់គ្រងផ្លូវនយោបាយរបស់សៀម គឺធ្វើប្រទេសខ្មែរឲ្យទៅជាអាណាព្យាបាលសៀមតែម្តង ( Faire du Cambodge un protectorat Siamois ) ដើម្បីទុកដែនដីនេះជាទ្រនាប់ទប់ទល់ នឹងការវាតទីតាំងរបស់សត្រូវថ្មីមួយនៃខ្លួន គឺយួននេះឯង ។ ដូច្នេះទំនាស់សៀម-ខ្មែរ មានលក្ខណៈជាជម្លោះរវាងប្រជាជាតិក្មេង និងប្រជាជាតិបុរាណមួយ ហើយជាការធម្មតាអារ្យធម៌ដែលមានយុវភាពតែងតែមានថាមពល ប្រៀបទៅលើអារ្យធម៌មួយទៀតដែលមានវ័យចាស់ ។ ហេតុនេះហើយបានជាយើងបាត់បង់អស់អាណាខេត្តជាច្រើន ។ ផ្ទុយទៅវិញ ជនជាតិយួនក្នុងដំណើររបស់ខ្លួនចុះមកទិសខាងត្បូងតាមបណ្តោយឆ្នេរសមុទ្រចាម និងកម្ពុជាក្រោម មានគោលបំណងនឹងវាតទីតាំងយកដែនដីត្រង់ៗតែម្តង គឺមិនមែនគ្រាន់តែចង់

យកអាណាចក្រខ្មែរ ធ្វើជាដែនដីអាណាខេត្តយួនទេ តែមានបំណងបំបាត់សាសន៍ខ្មែរ អារ្យធម៌ខ្មែរ, ពោលគឺធ្វើប្រទេសខ្មែរឲ្យក្លាយទៅជាដែនដីថ្មីរបស់យួននេះតែម្តង ។

នេះហើយជាហេតុការណ៍ ដែលអាចពន្យល់យើងឲ្យយល់នូវនយោបាយយួន ដែលបានប្រព្រឹត្តិមកលើជនជាតិខ្មែរ នៅសតវត្សរ៍ទី ១៨-១៩ និងនៅសតវត្សរ៍ទី ២០ ក្នុងដែនដីកម្ពុជាក្រោមសព្វថ្ងៃនេះ ។ បុព្វហេតុជាជម្រៅ នៃនយោបាយពង្រីកទឹកដីយួន នៅដែនដីឥណ្ឌូចិន គឺកំណើនចំនួនបណ្តាជនយួន ហើយនិងកង្វះខាតដែនដីដែលមានជីជាតិសម្រាប់ចិញ្ចឹមបណ្តាជនដែលរីកចំរើនយ៉ាងឆាប់រហ័ស។ គួរឲ្យកត់សំគាល់ផងដែរថា ក្នុងការ «ហែកដីខ្មែរចែកគ្នា» នេះហើយដែលសៀមនិងយួនប៉ះទង្គិចគ្នា ឯការប៉ះទង្គិចគ្នានេះក៏មានជាហូរហែមកហើយដែរលើដែនដីលាវ។ ជនជាតិសៀមក៏កាន់តែមានការមិនទុកចិត្តខ្លាំងឡើងចំពោះគូសត្រូវថ្មី គឺយួននេះឯង ។ ក្នុងករណីនេះ ក្នុងអនាគតកាល បើសៀមនិងយួនមានជម្លោះគ្នា គឺនៅលើទឹកដីខ្មែរ ឬលាវនេះតែម្តង ។

x

x x

# ១៥.០០០.០០០ នាក់ដល់ គ.ស. ២០០០ !

យើងបាននិយាយជាត្រួសៗរួចមកហើយ អំពីដែនដីភូមិភាគខ្លះក្នុងពិភពលោកយើងនេះ ដែលបានស្គាល់នូវកំណើនបណ្តាជនជាអតិបរមា ព្រមទាំងផលវិបាកនៃព្រឹត្តិការណ៍នេះទៀតផង។ យើងក៏អាចពិចារណាដល់ផលវិបាកបែបនេះដែលនឹងអាចកើតមានឡើង នៅលើភូមិភាគឥណ្ឌូចិន បើប្រសិនជាការវិវត្តន៍បណ្តាជននៅលើដែនដីនេះមានលក្ខណជាធម្មតា ( un évolution normale ) គឺថាបើគ្មានសង្គ្រាមឬអសន្តិសុខ ឬព្រឹត្តិការណ៍ដទៃទៀត មកធ្វើឲ្យស្ថានភាពនៃការវិវត្តន៍នេះផ្លាស់ប្តូរទេ ។

ដែលយើងរំពូកដល់បញ្ហានេះ មិនមែនយើងយល់សប្តិនោះទេ, គឺយើងនិយាយក្នុងឋានៈជាមនុស្ស ដែលមានសម្បជញ្ញៈគ្រប់គ្រាន់ជាមនុស្ស «ធម្មតា» ដែលពិចារណារកហេតុផល ។

យើងអាចគន់គូរធ្វើលេខរកចំនួនបណ្តាជនខ្មែរយើង ក្នុងរវាងឆ្នាំ ២០០០ បានដោយយកអត្រានៃកំណើនបណ្តាជន ( le taux d'accroissement démographique ) ២,៥ ឬ ២,៦ ភាគរយ[១] មកធ្វើមូលដ្ឋាន។ ហេតុដូច្នេះយើងអាចស្មានតាមវិធីវិទ្យាសាស្ត្រថា រវាងឆ្នាំ ២០០០ បណ្តាជនយើងនឹងឡើងទៅដល់ ១៤ ឬ ១៥ លាននាក់ហើយ នេះប្រសិនបើគ្មានសង្គ្រាមលោក ឬអសន្តិសុខណាមួយមករំខានការវិវត្តន៍នេះទេនោះៗ ឯចំនួនបណ្តាជនយើងនឹងឡើងទៅដល់៨០នាក់ក្នុង ១ គ.ម. ទ្វេគុណ ។ បើយ៉ាងនេះមែនយើងអាចសន្និដ្ឋានបានថា ក្នុង៣០ឆ្នាំទៀតដែនដីយើងមិនចង្អៀតចង្អល់នៅឡើយទេ។ ម្យ៉ាងទៀតដែនដីយើងជាវាលទំនាប សម្បូរទៅដោយជលធា មានទន្លេមេគង្គជាដើម, យើងនឹងអាចធ្វើរបៀបអាជីវកម្មកសិកម្ម( méthodes d'exploitation agricole ) រីតតែប្រសើរឡើង ដោយធ្វើឲ្យសម្រេចនូវការបាចទឹកបញ្ចូលស្រែ ( l'irrigation ) ឯដីដាំដំណាំយើងនៅសេសសល់ច្រើន ។ សព្វថ្ងៃនេះ ដីដាំដំណាំយើងមានតែ ១៨% នៃផ្ទៃ

---

(១) យោងទៅតាមស្ថិតិឆ្នាំ ១៩៦២, អត្រានេះមាន ២,៣% តែប៉ុណ្ណោះ តែបើតាមអ្នកជំនាញការ អត្រាដែលត្រឹមត្រូវជាង គឺ ២,៥% ឬ ២,៦% នេះឯង សូមមើល ( Les facteurs de croissance démographique au Cambodge thèse de doctorat de 3e cycle, Sorbonne Paris 1967.)

*ក្រឡាទាំងអស់តែប៉ុណ្ណោះ ។ យើងនឹងអាចបង្កើនទៅទៀត បើបណ្ដាជនយើងកើនច្រើនឡើងៗ ។*

*ហេតុដូច្នេះយើងសង្ឃឹមថា ដែនដីយើងមិនទាន់ចង្អៀតចង្អល់ទេ ក្នុង ៣០ ឆ្នាំ ឬ ៥០ ឆ្នាំខាងមុខនេះ, យើងនឹងអាចពង្រីកផលិតផលកសិកម្មថែមទៀត ។ ព្រោះថា ក្នុងអនាគតកាល មធ្យោបាយបច្ចេកទេសយើងក៏កាន់តែមានលក្ខណៈប្រសើរឡើងជាហូរហែដែរ ។ យើងនឹងមិនរន្ធត់ចំពោះអនាគតយើង ព្រោះប្រទេសយើងនឹងអាចចិញ្ចឹមដោយគ្រប់គ្រាន់នូវបណ្ដាជនរបស់យើងបានជាប្រាកដ ។ ប្រទេសយើងមិនចាំបាច់នឹងអនុវត្តន៍ នយោបាយពង្រីកទឹកដីនិយមទៅលើប្រទេសជិតខាងឡើយ ។*

*តែការដែលយើងគួរក៏យបារម្ភ គឺយើងចោទសួរខ្លួនយើងថា : តើអ្នកជិតខាងយើង, ខាងកើតយើងក្ដី ខាងលិចយើងក្ដី, នឹងទុកឲ្យយើងស្គាល់សន្តិភាពជារៀងដរាបឬ ? បើ ៣០ ឬ ៥០ ឆ្នាំទៀត ដែនដីរបស់គេនឹងពេញព្រៀប, ព្រៀបហាក់ដូចជាទឹកដែលពេញឈ្នាងទៅហើយ ។ ហូរហៀរចេញមកក្រៅ តម្រង់ទៅរកទីទំនាបដទៃទៀត។ តើយើងគួរចាត់ទុកថា ទីទំនាបដែលមិនទាន់ដក់ទឹកទាំងនេះ មាន* **វាលទំនាបទន្លេមេគង្គ និងទន្លេសាប** ( la vallée du Mékong ) *ពោលគឺប្រទេសកម្ពុជាយើង អាចជៀសផុតពីគ្រោះថ្នាក់នេះឬ ?*

x

x x




•ដំណើរសម្រុកចុះមកទិសខាងត្បូង•

-111 មុនគ.ស. មក 1840

តើយួនសម្រុកទៅទិសណាទៀត?

## គ្រោះថ្នាក់របស់យើងនៅទិសខាងកើត
## ជាង ៨០.០០០.០០០ នាក់រស់នៅលើផែនដីមួយយ៉ាងចង្អៀតចង្អល់

នៅទិសខាងកើតនិងខាងត្បូងប្រទេសកម្ពុជាយើង ជនជាតិយួនបានចុះសម្រុកមកពីទិសខាងជើង តាមឆ្នេរសមុទ្រអតីតនគរចម្ប៉ា ហើយបានធ្វើការទន្ទ្រានលុកលុយដណ្តើមដីធ្លីពីដូនតាយើង តាំងពីចុងសតវត្សរ៍ទី ១៧ មកម្ល៉េះ គ្រាន់តែក្នុងរយៈ ១៥០ ឆ្នាំប៉ុណ្ណោះ យួនបានមកវាតទីតាំង ព្រមទាំងក្លាយខ្លួនទៅជាម្ចាស់ទឹកដីកម្ពុជាក្រោម ពេញទីជាស្រេច (ក្នុង គ.ស. ១៨៤០)។ គួរតែយើងរំឭកដែរថា ជនជាតិយួនទាំងនេះដែលបានលេបស៊ីទឹកដីយើងមួយភាគយ៉ាងធំ មានទំហំ ៦៤.០០០ គ.ម. ទ្វេគុណគឺស្មើនឹងប្រទេសលង្កា (Ceylan) ទាំងមូលនេះបាន ក៏ដោយសារសម័យនោះបណ្តាជនយើងនៅកម្ពុជាក្រោម មានចំនួនតិចពន់ពេកណាស់ ថ្វីបើដែនដីតំណែលដូនតាយើងនេះ ជាដែនដីមួយដែលប្រកបទៅដោយដីជាតិជីវិសេសវិសាល រកដីឯណាមកប្រដូចពុំបានឡើយក៏ដោយ ។

ចំណែកឯការដែលយួនសម្រុកចុះមកខាងត្បូងនោះ បណ្តាលមកពីបុព្វហេតុថា បណ្តាជនកើតច្រើនពេក យួនពុំអាចមានដីល្អគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្នាគេបានឡើយ ។ ហេតុនេះហើយបានជាយួនបានធ្វើនយោបាយពង្រីកទឹកដីនិយម មកលើរាជាណាចក្រខ្មែរឥតឈប់ឈរ រហូតដល់សម័យបច្ចុប្បន្នកាលនេះទៀត ក៏យួនពុំព្រមបញ្ឈប់អំពើលួចចូលមកតាំងនៅលើដីដែលទំនេររបស់យើងឡើយ ។

សព្វថ្ងៃនេះ ប្រទេសវៀតណាមមានផ្ទៃក្រឡាប្រហែល ៣៣០.០០០ គ.ម² គឺធំជាងប្រទេសយើងចំនួនជិត២ដង។ គឺជាប្រទេសមួយដែលមានបណ្តោយដ៏វែងចំងាយពីខាងជើងមកត្បូងជិតតែ ២.០០០ គ.ម. ។ នាឆ្នាំ ១៩៧០ បណ្តាជនទាំងអស់នៃប្រទេសនេះ មានចំនួនជិតទៅ ៤០.០០០.០០០ នាក់ គឺ ២០ លាន ប៉ែកខាងជើង និង ១៨ លាន ប៉ែកខាងត្បូង ។ ប្រទេសវៀតណាម ជាដែនដីមួយសម្បូរទៅដោយព្រៃព្រឹក្សា និងភ្នំៗ ព្រៃនិងភ្នំនេះគ្របដណ្តប់លើផ្ទៃដី ៨០% នៃផ្ទៃក្រឡាទាំងអស់ គឺស្មើនឹងផ្ទៃក្រឡា ២៦០.០០០ គ.ម. ទ្វេគុណ ។ ហេតុដូច្នេះហើយបានជា, មនុស្សទាំង ៣៨ លាននាក់នេះរស់នៅលើផ្ទៃដីតែ ២០% តែប៉ុណ្ណោះ គឺស្មើនឹងផ្ទៃក្រឡា ៦០.០០០ គ.ម

ទន្លេគុណ ។ ក្នុងករណីក្រោយនេះ ដង់ស៊ីតេ ( densité ) ឡើងទៅដល់ ៦០០ នាក់ ក្នុង ១ គ.ម² ។ ដូចយើងឃើញស្រាប់ សព្វថ្ងៃនេះ ដីប្រទេសវៀតណាមនេះចង្អៀតចង្អល់ណាស់ទៅហើយ។ ចំណែកផលិតផលស្រូវអង្ករ ក៏សឹងតែមិនគ្រប់គ្រាន់ផង ។ ជម្រកស្រូវដ៏ធំនៃប្រទេសនេះគឺដែនដីសណ្ត ( le Delta ) នៃទន្លេមេគង្គ និងដីសណ្តទន្លេសុងកៃ ( le Delta du Fleuve Rouge ) ។ ដែនដីសណ្តទន្លេមេគង្គអាចផ្តល់ស្រូវអង្ករជាមធ្យម ៦ លានតោនក្នុងមួយឆ្នាំ ហើយដីសណ្តទន្លេសុងកៃផ្តល់ឲ្យ ៤ លានតោនជាមធ្យមដែរ ។ បូកទៅបានត្រឹមតែ ១០ លានប៉ុណ្ណោះ, ដូច្នេះទៅ ថ្ងៃមុខស្រូវអង្ករនេះប្រាកដជាមិនអាចបំពេញសេចក្តីត្រូវការរបស់បណ្តាជនយួន ដែលកំពុងកើនចំនួនយ៉ាងលឿនសោះឡើយ ។

ក្នុងចំណោមប្រទេសអាស៊ីទាំងឡាយ យួនមានអត្រានៃកំណើនប្រជាជន (taux d'accroisement démographique) ខ្ពស់ជាងគេឯង[១] គឺមានរហូតដល់ទៅជាង៣% ។ បើយោងទៅតាមភាគរយនេះ ក្នុងឆ្នាំ ១៩៧០ បណ្តាជនយួនរួមទាំងខាងជើងនិងខាងត្បូង នឹងឡើងដល់ទៅ ៤០.០០០.០០០ នាក់ ។

ក្នុងលក្ខណៈនេះ ប្រសិនបើការវិវត្តន៍របស់ប្រជាជននេះ មានល្បឿនទៅមុខទៀតដោយគ្មានព្រឹត្តិការណ៍ធំដុំអ្វីមករំខានទេ បណ្តាជនប្រទេសវៀតណាមនឹងឡើងរហូតទៅ ជាង ៨០.០០០.០០០ នាក់ ក្នុង ៣០ ឆ្នាំទៀត ។ ឯកម្ពុជាយើង ដល់ឆ្នាំ ២០០០ មានត្រឹមតែ ១៥ លាននាក់ប៉ុណ្ណោះ ។

x

x x

---

(១)-យោងទៅតាមសៀវភៅ :- « Les Deux Viet-Nam, Bernard Fall, Payot Paris, 1967.»
បើតាមលោក B. Fall, អត្រានៃកំណើននេះ ឡើងដល់ទៅ ៣,៥% បើតាមស្ថិតិផ្តល់ពីការជំរឿនប្រជាជនឆ្នាំ១៩៦០ នៅប្រទេសវៀតណាមខាងជើង។ ចំពោះវៀតណាមខាងត្បូង លោក B. Fall និយាយត្រឹមតែ ៣ ភាគរយតែប៉ុណ្ណោះ ។

## តើនឹងមានផលវិបាកធ្ងន់ធ្ងរអ្វីខ្លះ

*- យើងគួរចោទសួរដោយឆ្ងល់ថា ៖ តើដី ២០ ភាគរយនៃផ្ទៃក្រឡាទាំងអស់ ៣៣០.០០៩ គ.ម² ឬក៏ដីត្រឹមតែ ៦០.០០០ គ.ម² ប៉ុណ្ណោះ អាចផ្តល់អាហារគ្រប់គ្រាន់ឲ្យដល់មនុស្សជាង ៨០ លាននាក់បានឬទេ ?*

*ឆ្លើយវិញភ្លាមថា៖ ត្រឹមតែសព្វថ្ងៃ ៤០ លាននាក់ប៉ុណ្ណោះ ពិបាកនឹងចិញ្ចឹម ឲ្យបានរស់ក្នុងភាពគ្រប់គ្រាន់ទៅហើយ ចុះដល់ទៅ ៨០.០០០.០០០ តើនឹងកើតជាបញ្ហាធំយ៉ាងណាទៅ ?*

តើប្រទេសយៀកណាមនឹងក្លាយទៅជា «ជប៉ុន» ទី២ ក្នុងទ្វីបអាស៊ី ឬអាល្លឺម៉ាញទ្វីបអាស៊ីឬ ?

*ឆ្លើយ ៖*

*• ទី ១ ឬមួយក៏ប្រទេសយៀកណាម នឹងពង្រីកកម្លាំងឧស្សាហកម្មនិងសេដ្ឋកិច្ចជាអតិបរមា ប្រៀបប្រដូចបានទៅនឹងជប៉ុនទី ២ ក្នុងអាស៊ីភាគអគ្នេយ៍ ។ គំនិតនេះត្រូវបានអ្នកសង្កេតការណ៍អន្តរជាតិនានា យកមកគិតរួចជាមុនទៅហើយ គឺមុនកាលបញ្ចប់សង្គ្រាមយៀកណាមនេះទៅទៀត ។ ជាពិតប្រាកដមែនហើយ នេះគឺវិធានការប្រពៃណាស់ ។ ប្រទេសយៀកណាមសម្បូរទៅដោយធនធានរ៉ែ លោហធាតុ ថែមទាំងក្របខណ្ឌវិទ្យាសាស្ត្រ និងបច្ចេកទេស* ( techniciens, ingénieurs, chercheurs...) *ប្រកបដោយចំនួនច្រើនគ្រប់គ្រាន់ ហើយមានថាមពលទៀតផង បូករួមនឹងផ្សារក្នុងអនាគតដ៏ធំធេង (ជាង ៨០ លាននាក់), នឹងអាចក្លាយទៅពិតប្រាកដ ជាមហាអំណាចឧស្សាហកម្មយ៉ាងសំខាន់ក្នុងពិភពលោកយើងខាងមុខនេះ ។ កាលបើយៀកណាមក្លាយទៅជាឧស្សាហកម្មហើយ ប្រទេសនេះអាចលក់ចេញទៅបរទេស នូវផលិតផលឧស្សាហកម្ម ដើម្បីអាចទិញចូលមកវិញនូវផលិតផលកសិកម្ម ដើម្បីការត្រូវការខាងចំណីអាហារនៅក្នុងប្រទេស ។ គឺទាល់តែធ្វើយ៉ាងហ្នឹង ទើបបណ្តាជនប្រទេសនេះអាចរស់នៅបាន ដោយចៀសឲ្យផុតអំពីបញ្ហាសង្គម និងនយោបាយដែលនឹងរិតតែមានលក្ខណៈស្មុគស្មាញឡើង ។*

ចូរយើងនឹកគិតដល់**ប្រទេសជប៉ុន** ដែលក្នុងបច្ចុប្បន្នកាលនេះ មានផ្ទៃក្រឡាប្រហាក់ប្រហែលនិងយៀកណាមដែរ ( ៣៧០.០០០គ.ម$^{២}$ ) ហើយមានមនុស្សរស់នៅចំនួនជាង ១០០ លាននាក់ទៅហើយ ។ ស្ថានភាពនៃប្រទេសនេះ ពុំខុសពីប្រទេសយៀកណាមប៉ុន្មានឡើយ ៖ ក្នុងដី ៣៧០.០០០គ.ម២ ដីត្រឹមតែ ១៦ ភាគរយប៉ុណ្ណោះដែលគេអាចដាំដំណាំ ហើយរស់នៅបាន ។ ក្រៅពីនេះ គឺសុទ្ធសឹងតែភ្នំជ្រោះជ្រលងក្រំថ្មពុំអាចឲ្យមនុស្សរស់បានឡើយ ។ កាលពីរវាងឆ្នាំ ១៩៣០ ជប៉ុនបានស្គាល់នូវកំណើនប្រជាជនមួយយ៉ាងលឿន ហើយដើម្បីនឹងដោះស្រាយបញ្ហាខ្វះដីធ្លីនេះ ជប៉ុនបានអនុវត្តនូវនយោបាយពង្រីកទឹកដីនិយម យោធានិយមឈ្លានពានវាយដណ្តើមដែនដីពីប្រទេសចិន, ប្រទេសកូរ៉េ ។ល។ ប៉ុន្តែនយោបាយនេះបានត្រូវទទួលបរាជ័យក្រោយសង្គ្រាមលោកលើកទី ២ ជាស្រេចរួចទៅហើយ ។ ហេតុនេះហើយ បានជាជប៉ុនតម្រង់នយោបាយរបស់ខ្លួនមកវិញ រហូតដល់ក្លាយទៅជាមហាអំណាចសេដ្ឋកិច្ចទី ៣ ក្នុងពិភពលោក ( 3ème puissance économique modiale ) ក្រោយ ស.ស.ស (សូវៀត) ។

ដូចយើងឃើញស្រាប់ហើយ លក្ខណៈទឹកដី និងភូមិសាស្ត្រយៀកណាម និងជប៉ុនមានសភាពប្រហាក់ប្រហែលគ្នា ។ ដូច្នេះប្រហែលជាគ្មានកម្លាំងអ្វីអាចមករារាំងមិនឲ្យប្រទេសយៀកណាមក្លាយទៅជាមហាប្រទេសសេដ្ឋកិច្ចបានឡើយ, ហើយផ្សារដ៏សំខាន់នៃសេដ្ឋកិច្ចឧស្សាហកម្មនេះ គឺដែនដីអាស៊ីប៉ែកអគ្នេយ៍តែម្តង ។ល។

បើប្រសិនយ៉ាងនេះមែននោះ ប្រទេសកម្ពុជាយើងនឹងត្រូវទទួលរងគ្រោះជាដំណំ នឹងមិនអាចគេចផុតបានឡើង អំពីកម្លាំងយៀកណាមនេះ ព្រោះការវិវត្តន៍វាត្រូវតែយ៉ាងដូច្នោះ ! ចំពោះយើង បើសេដ្ឋកិច្ចនៅតែអោនថយ យើងនឹងក្លាយទៅជាផ្សារសេដ្ឋកិច្ចយួនតែម្តង។ នេះហើយជាទិដ្ឋភាពថ្មីមួយទៀតនៃលទ្ធិអាណានិគមនិយមសម័យថ្មី ដែលមានភាពសាហាវ មិនខុសពីអាណានិគមនិយមនយោបាយ ឬទឹកដីនោះសោះឡើយ។ នេះក៏របៀបម្យ៉ាងដែលនឹងនាំប្រទេសយើងឲ្យធ្វើដំណើរឆ្ពោះទៅរកការបាត់បង់ឯករាជ្យផងដែរ ។

តែក្នុងរយៈវេលាសព្វថ្ងៃនេះក៏ដោយចុះ ក៏គួរតែយើងព្រួយបារម្ភទុកឲ្យហើយ ព្រោះគ្រាន់តែយៀកណាមខាងត្បូងប៉ុណ្ណោះ គេបញ្ជូននិស្សិតគេទៅបរទេសក្នុង **មួយឆ្នាំរាប់ពាន់**[១] នាក់ ឲ្យទៅសិក្សាឧត្តមវិជ្ជានៅអឺរ៉ុបឬអាមេរិក។ ឯយៀកណាមខាងជើង

(១) យោងទៅតាមសៀវភៅលោក B. Fall, <Les deux Vietnam>, Payot, 1967, Paris, ទំព័រ ( ៣៦១ )

*វិញ និស្សិតបច្ចេកទេស វិស្វកររាប់ពាន់នាក់ត្រូវបញ្ជូនទៅរៀននៅសហភាពសូវៀតឬ អឺរ៉ុបប៉ែកខាងកើតនិងនៅប្រទេសចិន ។ល។ ទាំងក្រុមៗ តែម្ដងៗ លុះដល់សង្គ្រាមចប់ ភ្លាម ប្រទេសកុម្មុយនិស្តទាំងឡាយ រងចាំតែជួយកសាងសេដ្ឋកិច្ច, ឧស្សាហកម្ម, កសិកម្ម ប្រទេសនេះឡើងវិញ ។ ការជួយនេះជាកាតព្វកិច្ចសំខាន់ណាស់ ព្រោះ ប្រទេសកុម្មុយនិស្តទាំងឡាយ រមែងតែងមានសេចក្ដីសាមគ្គីគ្នាយ៉ាងជិតស្និទ្ធក្នុងគំនិត អន្តរជាតិនិយមប្រជាពលករ* ( dans l'intérêt de l'internationalisme prolétarien ) ។

*ម្យ៉ាងទៀត សង្គ្រាមនៅយៀកណាមខាងត្បូង មិនទាន់ចប់ស្រេចបាច់ផង ស្រាប់តែមូលធនបរទេស មានជប៉ុនដើមគេ រួចមកហុងកុង អាមេរិក សិង្ហបុរី ចូល មកធ្វើវិនិយោគ* ( investissements ) *យ៉ាងគគ្រឹកគគ្រេងក្នុងប្រទេសនេះទៅហើយ ចុះ ទំរាំសង្គ្រាមចប់ទៅ តើមូលធនបរទេសនឹងហូរចូលមកយ៉ាងណាទៀតទៅ ? ចុះ ចំណែកអាមេរិកាំងវិញ ប្រាកដជាមិនមែនចាកចេញពីប្រទេសយៀកណាម ដោយទុក ឲ្យប្រទេសនេះបាក់បែកខ្ទេចខ្ទីយ៉ាងដូច្នេះទេ, បើពុំនោះសោត ស.រ.អា. នេះនឹងត្រូវ អាមាសមុខយ៉ាងអាណោចអាធម្ម ចំពោះមតិសាធារណជនពិភពលោក ។ អាមេរិក ត្រូវតែលុបលាងកិត្តិយសរបស់ខ្លួន ។ ក្នុងឆ្នាំ ១៩៦៩ កន្លងទៅហើយនេះសភា អាមេរិកាំងបានទាំងគ្រោងថវិកាចំនួន ២.០០០.០០០.០០០ ដុល្លារ ( គឺត្រូវជាប្រាក់ រៀលជាង ១០០ កោដិ ) សំរាប់ស្ដាបនាប្រទេសយៀកណាមឡើងវិញ ។*

*ហេតុដូចខាងលើនេះហើយ បានជាមតិអ្នកសង្កេតការណ៍អន្តរជាតិខ្លះបានទាយ ថា ៖* ***ការរួបរួមគ្នាឡើងវិញនៃប្រទេសយៀកណាម ជាមហន្តរាយដ៏គគ្រឹប្រថុយប្រថាន ចំពោះអនា គតនៃមាតុប្រទេសកម្ពុជាយើង ។***

*បើប្រសិនជាយ៉ាងនេះមែន តើយើងនឹងអាចមានអ្វីអាចទប់ទល់រំងាប់កម្លាំង សេដ្ឋកិច្ចយួន កុំឲ្យវាចូលមកលេបសេដ្ឋកិច្ចយើងបានទេ ? បើមិនបានទេនោះ, តើ រវាង ៣០ ឆ្នាំទៀត យើងនឹងគង់វង្សជីវិតបន្តទៅទៀតបានឬទេ ?*

*ចំពោះកម្ពុជាយើង មាគ៌ាមានតែមួយគត់ សម្រាប់ការដោះស្រាយឲ្យបានគង់ វង្សជីវិត ។* ***មាគ៌ានោះ គឺការពង្រឹងកម្លាំងសេដ្ឋកិច្ចយើងឲ្យបានលឿនទាន់ហ៊ានទាន់កាល សម័យ ព្រោះមានតែកម្លាំងសេដ្ឋកិច្ចទេ ដែលអាចរំងាប់បាននូវកម្លាំងសេដ្ឋកិច្ចយួននេះ ។ ការបង្ខំឲ្យយើងយ៉ាងណាទៅទៀត គឺជាអំពើអត្តឃាតកម្ម គឺជាកំហុសធំណាស់ចំពោះប្រវត្តិសាស្ត្រ របស់មាតុភូមិជាទីស្នេហានៃ យើងរាល់គ្នា ។ ប្រវត្តិសាស្ត្រមានភ្នែក ។ ប្រវត្តិសាស្ត្រនឹងដាក់ទោសមកលើយើងរាល់គ្នាដែល ធ្វេសប្រហែសក្នុងបញ្ហានេះ ។***

**ទី ២** - ឬមួយក៏ប្រទេសយៀកណាម នឹងអនុវត្តនយោបាយបន្ថយចំនួនក្មេងកុំឲ្យកើតច្រើនពេក ( limiter les naissances ) ការនេះអាចនឹងសម្រេចបាន ក៏ស្រេចទៅលើការយល់ឃើញនៃអ្នកនយោបាយយួនក្នុងអនាគតតែប៉ុណ្ណោះ ។ បើទុកណាជានយោបាយជាយថាហេតុបែបនេះ អនុវត្តទៅប្រកបដោយជោគជ័យក្តី, ក៏ចំនួនបណ្តាជននៅច្រើនជាដរាប។ ប្រទេសយៀកណាមនៅតែពង្រីកកម្លាំងសេដ្ឋកិច្ច ឧស្សាហកម្មដដែល ព្រោះនេះជាកាតព្វកិច្ចខានពុំបាន ។ ហេតុដូច្នោះ គ្រោះថ្នាក់នៅតែមានលក្ខណៈធ្ងន់ធ្ងរដដែល មកលើវាសនានៃកម្ពុជាយើងទៅអនាគត ។
**ទី ៣** - តែប្រសិនជាផ្ទុយទៅវិញ កម្លាំងសេដ្ឋកិច្ចរដ្ឋយៀកណាមពុំបានលូតលាស់ឲ្យគ្រប់គ្រាន់ទេនោះ ហើយនយោបាយបន្ថយកំណើតកូនក្មេង ក៏ពុំត្រូវបានអនុវត្តទៀត នេះមហន្តរាយរឹតតែមានទំហំគុណពីរដង... ដប់ដង ។ល។ ខ្លាំងណាស់ទៅទៀត មកលើអនាគតប្រទេសកម្ពុជាយើង ។

ហេតុដូចម្តេចបានជាការនេះវាទៅជាយ៉ាងដូច្នោះវិញ ?

«សង្គ្រាម» នឹង «អាច» ផ្ទុះឡើងរវាងខ្មែរនិងយួន ពិបាកនឹងចៀសវាងបាន ព្រោះបណ្តាជនយួនកាន់តែកើនឡើងជាលំដាប់លំដោយ ៥០ ៦០ ៧០ ៨០ ៩០ លាន នាក់ក្នុង៣០ឆ្នាំទៀត។ ឯធនធានខាងសេដ្ឋកិច្ច និងខាងកសិកម្មនៅដដែលឬលូតលាស់យឺតពេក ជាហេតុពុំអាចនឹងអនុញ្ញាតឲ្យចិញ្ចឹមមនុស្សបានក្នុងភាពគ្រប់គ្រាន់ឡើយ ។

ការនេះនឹងបង្កើតឲ្យមានវិបត្តិផ្លូវសង្គម រួចវិបត្តិផ្លូវនយោបាយ បង្កបង្កើតឡើងដោយសេចក្តីមិនសប្បាយចិត្ត ឬភាពក្រវេទនារបស់ជនជាតិយួននោះឯង។ ពេលនោះហើយ នឹងមានអ្នកនយោបាយយួនខ្លះ ដែលជាអ្នកជាតិនិយមហួសហេតុ ( Les Vietnamiens Ultra-nationalistes ) បង្កបង្កើតឲ្យមានទ្រឹស្តីពង្រីកទឹកដីនិយម តាមរបៀបអាល្លឺម៉ាញជំនាន់ ហ៊ីត្លែរ ( Hitler ) ទាមទារនូវទឹកដីមួយដែលគេនឹងសន្មតថាគ្រប់គ្រាន់ សម្រាប់ការរស់នៅរបស់ប្រជាជនគេ ( une nouvelle théorie de l'Espace Vital ) ។ ហើយដែនដីដែលគេត្រូវការនោះ គឺមានតែកម្ពុជា-លាវ ឬសៀម(?) តែប៉ុណ្ណោះ ។ ដើម្បីនឹងសម្រេចនូវគម្រោងការនេះបាន នយោបាយឈ្លានពានបង្ករឿងហេតុ ឲ្យកើតទៅជាសង្គ្រាមឥណ្ឌូចិន «ទី ៣»(?) គេពុំងាយនឹងចៀសវាងបានឡើយ។

បើយ៉ាងនេះមែន នៅឯជើងមេឃនៃអនាគតដែនដីឥណ្ឌូចិននឹងមានពពកខ្មៅងងឹត មកបិទបាំងសេចក្តីសង្ឃឹមរបស់យើងរលត់សោះសូន្យ គួរឲ្យស្រណោះអាណោចអាធម្មក្រៃពេក។

ប្រសិនបើនយោបាយពង្រីកទឹកដីនិយម ដើម្បីរស់នេះត្រូវអនុវត្តមែននោះ ដែនដីយើង បណ្ដាជនយើងនឹងត្រូវគេលេបបន្តិចម្ដងៗ ហើយទីបំផុតនឹងរលាយរូបបាត់ឈ្មោះចេញពីផែនទីនៃពិភពលោក ដូចប្រវត្តិសាស្ត្រនៃរាជាណាចក្រចម្ប៉ា ឬដែនដីកម្ពុជាក្រោមឥតបើប្រកែកបានឡើយ ។

គឺពេលនេះឯងហើយ ដែលប្រវត្តិសាស្ត្រនឹងថែងអំពី « **ដំណើរឆ្ពោះទៅទិសខាងលិច** » នៃប្រជាជាតិយៀកណាម ក្រោមសន្ទុះនៃកំណើតជាអតិបរមានៃបណ្ដាជនមួយដែលឃ្លាំចាំឱកាសប្រល័យជីវិតយើង អស់រយៈកាលច្រើនសតវត្សមកហើយ ។

**រួមសេចក្ដី ៖** ដែនដីឥណ្ឌូចិនជាដែនដីមួយដែល ខ្វះស្ថេរភាពជានិរន្តរ៍ ។ នៅលើដែនដីនេះ ប្រទេសកម្ពុជាយើងក្នុងអនាគតកាលខាងមុខនេះ នឹងត្រូវឆ្លងកាត់នូវគ្រោះថ្នាក់ដ៏ធំធេងច្រើនបែបយ៉ាង ដូចជាការគំរាមកំហែងដល់ការគង់វង្សជីវិត ( la survie ) នៃប្រជាជាតិយើងទៀតផង ។ បើទុកជាការវិវត្តន៍នៅប្រទេសយៀកណាមទៅជាយ៉ាងណាក៏ដោយ, មហន្តរាយគ្រប់បែបនៅចាំឃ្លាំជីវិតយើងគ្រប់ជំហាន ។ ពេលវេលាដើរលឿនទៅមុខឆ្ងាយទៅៗ មហន្តរាយក៏លេចរូបរាងកាន់តែជំច្បាស់ឡើងៗ ជាលំដាប់ ។

គឺមានតែនយោបាយ ពង្រីកកម្លាំងសេដ្ឋកិច្ចជាតិឲ្យបានឆាប់រហ័សប៉ុណ្ណោះទេ ដែលអាចឲ្យយើងមានមធ្យោបាយទប់ទល់នឹងយថាហេតុគ្រប់បែបយ៉ាងបាន ។ តែនេះគឺគ្រាន់តែជានិក្ខេបបទ ( des thèses ) ជាទ្រឹស្តីឬមតិ ( l'opinion ) របស់មនុស្សម្នាក់តែប៉ុណ្ណោះ ដូច្នេះពុំទាន់ចាត់ទុកជាត្រឹមត្រូវបានការពេញលេញនៅឡើយទេ ។ ឯការពិតស្ថិតនៅលើប្រវត្តិសាស្ត្រក្នុងអនាគតកាលឯនោះវិញទេ ដែលអាចវិនិច្ឆ័យបាន...។

ក៏ប៉ុន្តែ យើងមិនមែនមានតែ «យួន» ទេដែលឃ្លាំចាំប្រល័យ នៅឯទិសខាងលិច «សៀម» ក៏ចាំតែឱកាសល្អនឹង «ក្រញេច» ដែនដីយើងដូចគ្នាដែរ ។

x

x x

# ប្រទេសសៀមនឹងមានបណ្ដាជន ៧០ លាននាក់

***នៅពីខាងជើង និង ខាងលិចប្រទេសកម្ពុជាយើង បណ្ដាជនប្រទេសមួយទៀតនឹងអាចក្លាយទៅជាទម្ងន់ដ៏ធ្ងន់មួយថ្មីទៀតសង្កត់មកលើដែនដីយើង . . . ។***

*កាលបើយើងបានលើកបញ្ហាយួនមកពិចារណា ពន្យល់បំភ្លឺដល់សម្បជញ្ញៈជាតិយើងរួចហើយ យើងពុំអាចបំភ្លេចបានសោះឡើយថា គ្រោះថ្នាក់ដែលនឹងអាចយាយីមាតុប្រទេសខ្មែរយើង មិនមែនធ្លាប់មានតែមកអំពីទិសខាងកើតនិងខាងត្បូងប៉ុណ្ណោះឡើយ, នេះគឺ «សត្រូវ» ចុងក្រោយរបស់យើង ដែលបានលេបរួចមកហើយនូវដែនដីយើង ដែលមានផ្ទៃក្រឡាជាង ៦០.០០០ គ.ម² ស្មើនឹងក្រឡាផ្ទៃប្រទេសអ៊ីស្រាអែលបីដង។ យើងនៅមានអ្នកជិតខាងរបស់យើងមួយទៀត ដែលជា«សត្រូវ» ចាស់ពីបរមបូរាណ ហើយដែលបានត្របាក់លេបជាច្រើនសតវត្សរ៍មកហើយ នូវអាណាខែត្ររបស់យើងយ៉ាងច្រើនអនេក ៖ «សត្រូវ» នេះ, ដែលយើងមិនទាន់អាចបំភ្លេចបានថា មុនឆ្នាំ ១៩០៧ បានមកវាតទីតាំងនៅលើ ១/៣ នៃដែនដីយើងសព្វថ្ងៃនេះ ហើយដែលកាលពីឆ្នាំ ១៩៤១ ដល់ ១៩៤៥ បានមកច្បាំងដណ្ដើមតាមវិធីកម្លាំងបាយនូវខែត្រសៀមរាប, កំពង់ធំ, បាត់ដំបងជាសាថ្មីទៀត* គឺប្រទេសសៀម ឬ ថៃឡង្គនេះឯង ។

*បើនៅក្នុងពង្សាវតាខ្មែរយើង ជនជាតិយួន ជាជនជាតិប្រកបដោយគ្រោះថ្នាក់យ៉ាងជាក់ស្ដែងចំពោះយើងយ៉ាងណា ជនជាតិសៀមក៏ជាអ្នកជិតខាងប្រកបដោយគ្រោះថ្នាក់ដែលមានសភាពសាហាវមិនចាញ់គ្នាយ៉ាងនោះដែរ ។*

*ដូច្នេះហើយ, ការដែលយើងចាប់អារម្មណ៍ទៅលើគ្រោះថ្នាក់ទាំងពីរនេះព្រមគ្នាជាមធ្យោបាយតែមួយ អាចឲ្យយើងប្រុងប្រៀបជើងការណ៍ទុកជាមុនឲ្យហើយ នេះប្រាកដជា* ***ឧត្ដមគតិដ៏ប្រសើរ*** *វិសេសវិសាលក្រៃលែងណាស់ទៅហើយ ប្រវត្តិសាស្ត្រពីអតីតកាលថ្មីៗ នេះជាមេរៀនស្រាប់, ការដែល «* ***ចាំឲ្យទឹកឡើងដល់ច្រមុះ*** *» សឹមប្រវេរប្រវារកទីជម្រក នឹងក្លាយទៅជាសេចក្ដីផ្ដើមនៃការលិចលង់ ឬទីបំផុតនៃភាពអស់សង្ឃឹមមិនខានឡើយ ។*

x

x x

# តើបណ្ដាជនសៀមអាចនឹងមានឥទ្ធិពល អ្វីទៅលើអនាគតនៃដែនដីរបស់យើង

ចម្លើយក្នុងភាពត្រឹមត្រូវមួយរយភាគរយ តបទៅសំណួរនេះវិញ, គ្មានជនណាមួយអាចធ្វើបានឡើយ តែគេអាចធ្វើសេចក្ដីសន្និដ្ឋានក្នុងភាពប្រហាក់ប្រហែល មានបែបផែនជានិក្ខេបបទ ( des thèses ) បានខ្លះៗ ។

តាមឯកសារសរសេរដោយលោក ឡាលូប៊ែរ ( La Loubère ) ក្នុងរវាងឆ្នាំ ១៦៩៣ បណ្ដាជនសៀមមានត្រឹមតែ ១.៩០០.០០០ នាក់តែប៉ុណ្ណោះ ។ ជាងមួយសតវត្សរ៍កន្លងមកទៀត គឺក្នុងគ.ស.១៨៤១, បណ្ដាជននេះកើនដល់ទៅ ៥.២០០.០០០នាក់ (នៅរយៈពេលប្រហែលគ្នានោះ ខ្មែរយើងមានប្រហែល ៨០០.០០០ នាក់)។ រួចហើយបណ្ដាជននេះក៏កើនចំនួនទៅជា ៨.២០០.០០០ នាក់នាឆ្នាំ ១៩១០, រួច ១៤.៥០០.០០០ នាក់នាឆ្នាំ ១៩៣៧, រួច ២២.៨០០.០០០ នាក់នាឆ្នាំ ១៩៥៦ ។ គ្រាន់តែក្នុងឆ្នាំ ១៩៦៥ តែប៉ុណ្ណោះ បណ្ដាជននេះកើនដល់ទៅ ៣០ លាននាក់ស្រេចទៅហើយ ។ តាមការគន់គូរតាមរបៀបវិទ្យាសាស្ត្រ ដល់ឆ្នាំ ១៩៧៥ ខាងមុខនេះនឹងឡើងដល់**៤០លាននាក់** [១] ។

ដូចជាយើងបានឃើញនេះស្រាប់ បណ្ដាជនសៀមកើនលឿនរហ័សជាពន់ពេក ហើយជាពិសេសទៅទៀត គឺចាប់តាំងពីក្រោយសង្គ្រាមលោកលើកទីពីរមក ។

កំណើនដ៏លឿននេះ បណ្ដាលមកអំពីការចុះថយជាច្រើននៃចំនួនមនុស្សស្លាប់ក្នុងមួយឆ្នាំៗ ហើយផ្ទុយទៅវិញ ចំនួនមនុស្សកើតកាន់តែមានសន្ទុះលឿនទៅមុខឥតឈប់ឈរសោះ ។ មុនឆ្នាំ ១៩៥០ គេបានចាត់ទុកប្រទេសថៃឡង់នេះ ជាប្រជាជាតិដែលសម្បូរសប្បាយរស់ក្នុងសេចក្ដី «ស្ងប់ស្ងាត់» គ្មានបញ្ហាចោទសោះឡើយ ។ ឥឡូវនេះ, អស់ហើយភាពសម្បូរសប្បាយ អស់ហើយភាព «ស្ងប់ស្ងាត់» បញ្ហាដ៏ច្រើនសែនកំពុងតែចោទឡើង គឺបុព្វហេតុនៃបញ្ហានេះ គឺបណ្ដាលមកអំពីកំណើនដ៏ឆាប់នៃបណ្ដាជនសៀមនេះឯង ព្រមទាំងការវិវត្តន៍នៃស្ថានភាពនយោបាយអន្តរជាតិក្នុងភូមិភាគអាស៊ីប៉ែអគ្នេយ៍នេះមកបូកបន្ថែមទៀត ។

---

(១) យោងទៅតាមសៀវភៅ <l'Evolution de la Thailande contemporaine> Cahier de la Fondation Nationale des Sciences, Politiques, P. Fistié, Paris, 1967, et " la Thailande", Q.S.J., P.U.F., Paris, 1963.

***ប្រទេសថៃឡង់*** ៖ ៧០.០០០.០០០ ដល់ឆ្នាំ ២០០០ !

*បើតាមស្ថិតិដែលត្រូវបានគេសម្រេចឡើង តាមបែបបទវិទ្យាសាស្ត្រ កំរិតអត្រានៃកំណើនបណ្ដាជនសៀមឡើងដល់ទៅ ៣,០០%*[១] *ឯខ្មែរយើងមានត្រឹមតែ ២,៦% តែប៉ុណ្ណោះ ។*

*ហេតុដូច្នេះហើយ បើប្រសិនជាគ្មានព្រឹត្តិការណ៍ឯណាមករំខានដល់ការវិវត្តន៍នេះទេ ប្រទេសសៀមនឹងអាចមានមនុស្សដល់ជិតទៅ ៧០ លាននាក់ នាដើមសតវត្សទី ២១ ខាងមុខនេះ ( ឯកំណើនបណ្ដាជនខ្មែរយើងនឹងឡើងដល់ ១៥ លាននាក់តែប៉ុណ្ណោះ ) ។*

*ហេតុដែលបណ្ដាជនសៀមនេះ កើនក្នុង ៣០ ឆ្នាំខាងមុខនេះដល់ទៅ ៧០ លាននាក់នេះ មិនមែនជាការមួយគួរឲ្យយើងនៅស្ងៀមព្រងើយកន្តើយសោះឡើយ។ ដែនដីឥណ្ឌូចិន នឹងក្លាយទៅជាដែនដីដែលមានបណ្ដាជនច្រើនហួសមាឌ* ( Une région surpeuplée ) *។ គ្រាន់តែសៀមនិងយួនបូកបញ្ចូលគ្នាកើនដល់ទៅជាង* ***១៥០ លាននាក់*** *យើងដែលមានត្រឹមតែ ១៥ លាន គឺ ១ ប្រឆាំងនឹង ១០ នឹងមានមធ្យោបាយគ្រប់គ្រាន់អាចតតាំងនឹង ( សត្រូវ ) យើងបានទេ, បើគេរួមគ្នាជាធ្លុងមួយហើយអនុវត្តនូវបំណងអាក្រក់មកលើប្រទេសយើង ។ ប្រទេសយើងគឺជាដែនដីមួយដែលមាន ស្ថានភាពភូមិសាស្ត្រនយោបាយ* ( Une position géo-politique centrale ) ***នៅកណ្ដាលគេ,*** *ហើយដែលគេ ( ប្រសិនបើគេត្រូវរ៉ូវគ្នា ) កៀបសង្កត់ពីគ្រប់ទិសទីបានដោយងាយ ។ បើយើងនឹងរើសយកឧទាហរណ៍ក្នុងលោកនេះមកពន្យល់បាន គឺស្ថានភាពភូមិសាស្ត្រប្រទេស* ***ប៉ូឡូញ*** *នេះតែម្ដង ។ ចូរយើងមើលចុះ ប្រទេសប៉ូឡូញនេះ, ជួនកាលត្រូវបាត់បង់ដែនដី, បាត់ឈ្មោះពីផែនទីនៃពិភពលោក, ជួនកាលទៀត ប្រទេសអាល្លឺម៉ាញពីខាងលិចនិងប្រទេសរុស្ស៊ីពីខាងកើតស្រុះស្រួលគ្នា «ហែកដែនដីចែកគ្នា» ដូចកាលពីសម័យសង្គ្រាមលោកលើកទី ២ នេះស្រាប់ ។ល។*

ដូច្នេះហើយ, ក្នុងអនាគតកាលនេះ បញ្ហាធំដែលចោទមកលើឥណ្ឌូចិន គឺបញ្ហាចង្អៀតចង្អល់នៃដែនដី ដែលបណ្ដាលមកពីបណ្ដាជនច្រើនហួសមាឌនេះឯងជាប្រាកដ ។

---

*(១) យោងទៅតាមសៀវភៅ :* <L'Evolution de la Thailande Contemporaine> *ដដែលនិង* <L'Economie de l'Asie du Sud Est> Lè Thanh Khoi, P.U.F. Paris, 1964.

# ផលវិបាក បណ្ដាលមកអំពីកំណើន
# បណ្ដាជនក្នុងប្រទេសសៀម

តើរដ្ឋាភិបាលសៀមនឹងដោះស្រាយបែបណា ចំពោះបញ្ហាកំណើនចំនួនបណ្ដាជននេះ ?

គ្រាន់តែក្នុងសព្វថ្ងៃនេះ ដែលបណ្ដាជនមិនទាន់ទាំងកើនដល់ ៤០ លាននាក់ផង នោះ បានបង្កើនឲ្យមានការព្រួយបារម្ភមួយយ៉ាងធំធេងក្នុងចំណោមអ្នកដឹកនាំសៀមៗ នាឆ្នាំ ១៩៥៧-៥៨, តាមសេចក្ដីសុំពីរដ្ឋាភិបាលសៀម បេសកកម្មមួយនៃ ធនាគារពិភពលោក ( la B.I.R.D. ) បានមកធ្វើការសិក្សានិងសេចក្ដីរាយការណ៍មួយ អំពីស្ថានភាពសេដ្ឋកិច្ចសៀម ។ យោបល់រួមនៃសេចក្ដីរាយការណ៍នេះ បានបង្ហាញឲ្យឃើញនូវកង្វះខាត និង ភាពខ្សត់ខ្សោយជាច្រើនចំពោះអនាគតសេដ្ឋកិច្ចសៀម ។

ផ្ទុយទៅវិញ, ការពង្រីកធនធានសេដ្ឋកិច្ច គឺបង្កើនផលិតផលកសិកម្មនិងឧស្សាហកម្មជាការចាំបាច់ ដើម្បីដោះស្រាយបញ្ហាកំណើនបណ្ដាជននេះ, ដើម្បីរក្សាកុំឲ្យកំរិតជីវភាពនៃប្រជារាស្ត្រធ្លាក់ចុះជាលំដាប់ រហូតដល់ភាពវេទនាក្រខ្សត់ ខ្វះចំណីអាហារបរិភោគ ។

សម័យបច្ចុប្បន្ននេះ ធនធានសេដ្ឋកិច្ចខ្លះៗ ដែលពីមុនអាចត្រូវគេនាំចេញទៅបរទេសបាន ក៏កាន់តែមានចំនួនអោនថយជាលំដាប់ មានឈើម៉ៃសាក់, សំណ, ប៉ាហាំង, កៅស៊ូ, ហើយពិសេសទៅទៀត គឺអង្ករនេះតែម្ដង ។

ហេតុដូច្នេះហើយ បានជាការពង្រីកសេដ្ឋកិច្ចឲ្យបានលឿនឆាប់រហ័ស បានក្លាយទៅជាអាទិភាពទីមួយ នៃនយោបាយសៀម ។

គឺក្នុងគំនិតនេះហើយ ដែលរដ្ឋាភិបាលសៀមសព្វថ្ងៃនេះ កំពុងតែស្ថាបនាគម្រោងការណ៍ធំៗ ជាច្រើន មានសំណង់ទំនប់ជលាគ្គីសនី ដែលអាចឲ្យសម្រេចជាមួយផង នូវការបាចទឹកបញ្ចូលស្រែ ( l'irrigation ) នឹងអាចពង្រីកនូវផ្ទៃដីដាំដំណាំថ្មីៗទៀត ។ រីឯខាងវិស័យឧស្សាហកម្មវិញ មូលធនបរទេស (les capitaux étrangers) ជាច្រើនបានត្រូវគេប្រើប្រាស់ក្នុងប្រទេស ដើម្បីសម្រេចឲ្យមាននូវការចំរើនលូតលាស់ៗ ក្នុងចំណោមមូលធនប្រទេសដែលគេបានធ្វើវិនិយោគក្នុងប្រទេសនេះ គឺមានមូលធនជប៉ុនច្រើនជាងគេ, បន្ទាប់មកមូលធនចិនតាយ-វ៉ាន់ ហើយទី៣ គឺមូល

ធនអាមេរិកាំង ។ ក្នុងនយោបាយសេដ្ឋកិច្ចនេះ រដ្ឋាភិបាលបានធ្វើការសម្រួលឲ្យជាអតិបរមា ដល់ការនាំចូលមកនៃមូលធនបរទេសទាំងនេះ ។

កំប៉ុន្តែ បញ្ហាដែលសំខាន់ជាងគេ គឺបញ្ហាស្រូវអង្ករនេះឯង ។ វាលទំនាបនៃទន្លេមេណាម ជាមហាជង្រុកស្រូវនៃប្រទេសសៀម ។ ក្នុងកាលសព្វថ្ងៃនេះ ផ្ទៃក្រឡាដីដាំដំណាំ មានចំនួនតែ ១/៤ តែប៉ុណ្ណោះ នៃវាលទំនាបទន្លេមេណាម ដែលសម្បូណ៌ទៅដោយជលធារ ។ ដូច្នេះបញ្ហានៃការពង្រីកដីដំណាំមិនមែនចោទក្នុងលក្ខណៈធ្ងន់ធ្ងរដូចនៅប្រទេសយៀកណាមនោះទេ ។ ដែនដីសៀមដែលមានផ្ទៃក្រឡាទាំងអស់ជាង ៥០០.០០០ គ.ម² ហើយដែលមួយភាគយ៉ាងធំជាដីទំនាប នឹងមិនទាន់ក្លាយទៅជាដីចង្អៀតចង្អល់នៅឡើយទេ ក្នុងរយៈកាល ៣០ ឬ ៥០ ឆ្នាំទៅខាងមុខនេះ ។ ប្រទេសនេះ អាចនឹងបង្កើនផលិតផលកសិកម្មបានថែមទៀត ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការកាន់តែធំឡើងៗនៃប្រជារាស្ត្រ ដោយសារនយោបាយធ្វើឲ្យរឹតតែប្រសើរឡើង នូវរបៀបអាជីវកម្មកសិកម្ម មានការបាចទឹកបញ្ចូលស្រែ ការប្រើជីគីមី ឬប្រើគ្រឿងយន្តកសិកម្ម ។ គឺក្នុងបំណងនេះឯងហើយ ដោយរដ្ឋាភិបាលសៀមកំពុងតែអនុវត្តគម្រោងការធំៗ ជាច្រើន ខាងទំនប់ទឹក ជីកប្រឡាយបញ្ចូលស្រែ តាំងពីឆ្នាំ ១៩៥០ មកម៉្លេះ ដោយសារជំនួយពិភពលោក ។ គម្រោងការនេះ អាចពង្រីកនូវផ្ទៃក្រឡាដីដាំដំណាំ ព្រមទាំងថាមពលអគ្គីសនីទៀតផង ។

ប្រសិនបើគម្រោងការពង្រីកផលិតផលកសិកម្ម និងធនធានឧស្សាហកម្មនេះមានជោគជ័យមែន បញ្ហាវិបត្តិផ្លូវសង្គមអាចនឹងត្រូវបានដោះស្រាយឲ្យបានធូរស្រាលខ្លះ, កំប៉ុន្តែកម្លាំងសេដ្ឋកិច្ចសៀម នឹងរឹតតែមានទំហំធំឡើងជាលំដាប់ អាស្រ័យទៅលើភាពធំធេងនៃផ្សារក្នុងប្រទេសសៀមនេះជាប្រាកដ (ពី ៦៥ ទៅ ៧០ លាននាក់ ដល់ចុងសតវត្សរ៍ទី ២០) ។ ក្នុងករណីនេះ ការពង្រីកកម្លាំងសេដ្ឋកិច្ចសៀមនេះ កំអាចក្លាយទៅជាគ្រោះថ្នាក់មួយធំដែរ ទៅលើអនាគតប្រទេសកម្ពុជាយើង ដែលមានផ្សារក្នុងប្រទេសខ្សោយនៅឡើយ ។ ជាការពិតមែនហើយ កម្លាំងសេដ្ឋកិច្ចក្នុងតំបន់និមួយៗនៃពិភពលោក ប្រៀបបានទៅនឹងកម្លាំងទឹកដែលហូរហៀរ ពីតំបន់មួយខ្ពស់ទៅតំបន់មួយទៀតដែលទាបជាងដូច្នេះដែរ ។

ឯប្រទេសកម្ពុជាយើង ដែលស្ថិតនៅកណ្តាលប្រទេសទាំងពីរនេះ ទុកជាយើងធ្វើយ៉ាងណា ៗ ក្តី កំពុំអាចចៀសផុតអំពីការសង្កត់សង្កិនកាន់តែធ្ងន់ធ្ងរឡើងខាងផ្លូវសេដ្ឋកិច្ច និងបណ្តាជន ( les pressions d'ordre économique et démographique

grandissantes ) នៃប្រទេសទាំងសងខាងបានរួចឡើយ ដោយអាស្រ័យទៅលើហេតុថា គេពុំអាចធ្វើព្រំប្រទល់ដែនឯណាឲ្យបិទជិតសូន្យឈឹងបានឡើយ រវាងប្រទេសជិតខាងគ្នា ។

តើប្រទេសកម្ពុជាយើង ដែលមានលក្ខណៈជាដែកទ្រនាប់មួយតូច អាចទ្រទ្រង់ទប់ទល់នឹងញញួរធំៗ ដល់ទៅពីរដែលធ្លាក់មកលើខ្លួនព្រមៗ គ្នាបានឬទេ ក្នុងអនាគតខាងមុខនេះ ? វាជាការពិតណាស់ទៅហើយ, ដើម្បីនឹងអាចទ្រាំទ្របាន លុះត្រាតែដែកទ្រនាប់នេះ ត្រូវគេបន្ថែមស្រទាប់ដែកឲ្យបានក្រាស់មាំជាងមុនទើបបាន ។

ម្យ៉ាងទៀត ចំពោះករណីសៀមនេះទៀតសោត បើសិនជាប្រទេសនេះអាចសំរេចដោយជោគជ័យខាងការពង្រីកកម្លាំងសេដ្ឋកិច្ចបាន នោះជាការប្រសើរហើយ ។ តែបើផ្ទុយទៅវិញ, តើនឹងមានការដោះស្រាយឯណាទៀត ? ច្បាស់ជាអ្នកដឹកនាំសៀមនេះនឹងចោលភ្នែកញយៗ មកលើ ដែនដីដ៏មានជីជាតិនៃខេត្តបាត់ដំបង និងវាលទំនាបនៃបឹងទន្លេសាប ដែលសម្បូរទៅដោយត្រីសាច់ និងស្រូវអង្ករមិនខានឡើយ ។ ចុះបើគេឃុបឃិតជាមួយជនជាតិយួនទៀត ដើម្បីបែងចែកផែនដីយើង, ដូចនៅសតវត្សរ៍ទី ១៩ នាឆ្នាំ ១៨៤០ តើយើងនឹងឈមមុខទប់ទល់នឹងគម្រោងការអកុសលនេះតាមវិធីណា ?

x

x x

# សេចក្ដីបញ្ចប់

*ទាំងអស់នេះ, គឺគ្រាន់តែជាការសន្និដ្ឋាន ការប្រមើលមើល ដែលជាលទ្ធផលនៃប្រាជ្ញានឹងការយល់តែប៉ុណ្ណោះ មិនទាន់មានជាការពិតនៃប្រវត្តិសាស្ត្រនោះឡើយ ។ តែ, តើនរណាឡើយដែលអាចហ៊ានអះអាងថា ក្នុងអនាគត, ការប្រមើលមើលនេះមិនអាចក្លាយជាដាច់ខាត ទៅជាការពិតក្នុងប្រវត្តិសាស្ត្របាន ? ប្រវត្តិសាស្ត្រអាចឲ្យមេរៀនផង មិនឲ្យមេរៀនផងចំពោះយើងរាល់គ្នា ។ អនាគតកាលគឺជារូងងងឹតមួយដែលគេតម្រូវឲ្យយើងចូលទៅក្នុង ដោយឥតប្រកែកបានឡើយ តែបើយើងដឹងមុនថារូងនេះមានកិនកាគយ៉ាងម៉េចៗ ខ្លះហើយ, យើងក៏អាចប្រុងប្រៀបខ្លួនយើងបានច្រើនដែរ ដើម្បីឈមមុខនឹងយថាហេតុគ្រប់យ៉ាង ។*

*ហេតុដូចបានអធិប្បាយដោយត្រួសៗ ពីខាងលើនេះ យើងអាចសន្មតដោយមានការកាន់ច្រឡំជាអប្បបរមាថា ចំពោះអនាគតកាលនៃប្រទេសកម្ពុជាយើង,* ឯនាយជើងមេឃឯណោះ សុទ្ធតែប្រកបទៅដោយដុំពពកខ្មៅៗ ច្រើនជាអនេក *កម្លាំងនៃការសង្កត់សង្កិនខាងផ្លូវសេដ្ឋកិច្ចជាមួយគ្នានឹងផ្លូវបណ្ដាជន និងផ្លូវនយោបាយថែមទៀតផង ជាការគំរាមកំហែងមួយយ៉ាងធំឥតប្រៀបផ្ទឹមបាន ដែលប្រទេសយើងត្រូវតែទទួលរងគ្រោះពីសំណាក់នៃអនាគតប្រទេសជិតខាងយើង ។*

*ក្នុងលក្ខន្តិកៈបែបនេះ, មាគ៌ាដែលយើងត្រូវដើរ គឺយើងត្រូវមានកាតព្វកិច្ចជាបឋម រៀបចំសេដ្ឋកិច្ចជាតិយើងឲ្យដើរលឿនទាន់សម័យនិយម, ធ្វើសេដ្ឋកិច្ចនេះឲ្យរីកចំរើនជាអតិបរមា ដើម្បីអាចឲ្យមានកម្លាំងគ្រប់គ្រាន់ អាចឈមមុខទប់ទល់បាននឹងកម្លាំងសង្កត់សង្កិនពីអ្នកជិតខាងយើង ដោយធ្វើឲ្យការគំរាមកំហែងដល់ការគង់វង្សជីវិតយើងមានទំហំយ៉ាងតូចបំផុត ។*

បើសេដ្ឋកិច្ចមានកម្លាំងគ្រប់គ្រាន់ហើយ, នយោបាយក៏ដើរតាមសេដ្ឋកិច្ចពីក្រោយខ្នងដែរ សមនឹងពាក្យដែលថា គឺសេដ្ឋកិច្ចទេដែលនាំនយោបាយ ។ គំនិតទាំងអស់នេះ គឺគ្រាន់តែជាលទ្ធផលនៃការត្រិះរិះពិចារណាស្ដួចស្ដើងនៃមនុស្សម្នាក់តែប៉ុណ្ណោះ ដូចនេះពុំទាន់មានលក្ខណៈជាសាកលឡើយ។ ហេតុដូច្នេះហើយ ការភាន់ច្រឡំមិនច្បាស់លាស់តែងមានជាការធម្មតា ។

បំណងរបស់យើងគឺ ការសាកល្បងបំភ្លឺអនាគតកាលនិងសម្បជញ្ញៈតែប៉ុណ្ណោះ ។

គ្រង់បញ្ហាពង្រីកសេដ្ឋកិច្ចឲ្យបានជឿនលឿននេះ ស្រេចតែសមត្ថកិច្ចបច្ចេកទេស ខាងផ្នែកនេះចុះ ។

. . សូមប្រទេសកម្ពុជា ជាមាតុភូមិជាទីស្នេហា គង់វង្សជានិច្ច. . . ក្នុងភាពថ្កុំថ្កើង ។

កំពង់ចាម ថ្ងៃទី ២០ មករា ១៩៧០

**នួន យឿន**

*វាយសាឡើងវិញ និងរចនាអក្សរក្រុប : យុនពីម៉ូច*
*កែសំរួលពាក្យបារាំង និងរូបភាពផែនទីថ្មី : មាន់ព្រឹក*
*ជួយពិនិត្យអក្ខរាវិរុទ្ធខ្មែរ : ចិនខ្មៅ*
*ស.រ.អា., ៧មេសា២០០៨.*